**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# អសាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី១៩)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

អសាធារណៈ

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ បេ៊ត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទួអាត ហ្វដ *(Mr. Stuart FORD)*

លោក ប៉ាក ចន្ទលីណូ

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms.Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោក គឹម ម៉េងឃី

កញ្ញា ទី ស្រ៊ីនណា

លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វែ៊នណឺ*(Mr. Alain Werner)*

លោកស្រីអេលីហ្សាប៉ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊ែត | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោកស្រី ជា លាង | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| លោក រ៉ូបឺត ពេទិត | ខ្មែរ |
| លោកស្រី វ៉ាបេសាន់ដ្រាតាណា | បារាំង |
| លោក ហ្វ្រង់ ស្វ័រ រូ | បារាំង |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី ស៊ីលឃិ ស្តូតហ្សីនស្គី | អង់គ្លេស |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

*[សវនាការអសាធារណៈចាប់ផ្តើមពីម៉ោង ០៩:២៥ នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ស្ទួតហ្សីនស្តី ចង់មានយោបល់រឿងអីទៅ?

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

សូមអរគុណលោកប្រធាន ។ ជាទូទៅ ខ្ញុំសូមបញ្ចេញមតិនេះជាសាធារណៈទាក់ទងទៅនឹងការមិនបញ្ចូលភាគីដើមបណ្តឹងរដ្ឋប្បវេណីនេះ ។ ប៉ុន្តែ ឥឡូវនេះខាងក្រុមដើមបណ្តឹងរដ្ឋប្បវេណី គឺថាត្រូវបានគេមិនបញ្ចូលរួចទៅហើយ ។ ហើយខ្ញុំមិនទាន់មានឱកាសដើម្បីលើកឡើងអំពីចំណុចនេះ ហើយខ្ញុំមិនឃើញមានវិធានណាមួយដែលថា ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏មេធាវីហ្នឹងឯងត្រូវបានដកចេញនៅពេលដែលអង្គសវនាការធ្វើសេចក្តីប្រជុំ ឬក៏សវនាការជាអសាធារណៈនេះ ពីព្រោះអីនៅក្នុងការប្រជុំការរៀបចំធ្វើសវនាការនោះ ក៏មានបានលើកឡើងពីចំណុចនេះដែរ ។ ហើយខ្ញុំសូមស្នើទៅលោកប្រធានហើយខ្ញុំចង់ធ្វើការនិយាយលើកចំណុចនេះផងដែរ ជាសាធារណៈ បើសិនជាមានឱកាសនោះ ។

ហើយខ្ញុំសូមស្នើឲ្យខាងដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងចូលរួមនៅក្នុងសវនាការអសាធារណៈនេះផងដែរ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា ដំបូងគឺមានបញ្ហាបច្ចេកទេស ពីព្រោះខាងផ្នែកសោតទស្សន៍ គឺថាអាចឮបាននៅក្នុងសាលសាធារណៈ ។ ដូច្នេះ យើងត្រូវរៀបចំពិនិត្យមើលលើបញ្ហានេះឲ្យបានច្បាស់លាស់សិន ។

មានន័យថា យើងធ្វើយ៉ាងម៉េចឲ្យសវនាការនេះជាសវនាការអសាធារណៈសិន ។

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះគឺ លោកស្រី ស្ទួតហ្សីនស្តី មានបានលើកឡើងអំពីការនូវមូលហេតុនៃការដែលមិនអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីបួនរូប ដែលគាត់មានវត្តនៅក្នុងសាលសវនាការ ។ ហើយបញ្ហានេះ គឺអង្គជម្រះសូមជម្រាបដល់ភាគីពាក់ព័ន្ធថា នេះជាបច្ចេកទេសនៅក្នុងការពិភាក្សាគ្នា ដើម្បីរកដំណោះស្រាយដែលមានចម្រូងចម្រាសគ្នា ក្នុងអំឡុងពេលពីម្សិលមិញយ៉ាងតឹងតែង ដើម្បីរកដំណោះស្រាយផ្នែកបច្ចេកទេស ដើម្បីឲ្យដំណើរការទៅមុខបានតែប៉ុណ្ណោះ ។ យើងមិនចូលជ្រៅទៅលើពាក់ព័ន្ធជាមួយនឹងរឿងក្តី ខ្លឹមសារអង្គហេតុនៃរឿងក្តីដែលការពាក់ព័ន្ធទេ ។ ហើយអ៊ីចឹងគឺសំណូមពររបស់

លោកស្រី ស្ទូតហ្វឺនស្ដី គឺអង្គជម្រះច្រានចោល ហើយសុំប្រគល់សិទ្ធិថាទុកសិទ្ធិជូនលោកស្រីអាចលើកឡើងបាននៅពេលណា ដែលលោកស្រីជាសាធារណៈ លោកអាចធ្វើការកត់សម្គាល់អំពីចំណាត់ការរបស់អង្គជំនុំជម្រះអំពីថា មិនអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប៉ុន្មាននាក់ចូលនេះបាននៅពេលក្រោយ នៅពេលដែលបើកទូលាយជាសាធារណៈវិញ ។

អ៊ីចឹងយើងបញ្ជាក់ជាថ្មីម្ដងទៀតថានេះ គឺជាពិភាក្សាអំពីបច្ចេកទេសនៃការដំណើរការពិភាក្សាដេញដោលរកដំណោះស្រាយដែលត្រឹមត្រូវ ដែលសមរម្យអាចទទួលយកបានគ្រប់ភាគីដើម្បីដំណើរការទៅ ។ ចៀសវាងការទន្ទឹងរងចាំរបស់សាធារណជនដែលកំពុងតែទន្ទឹងរង់ចាំហើយ បច្ចេកទេសនៅក្នុងការដំណើរការប្រព្រឹត្តទៅនៃកិច្ចពិភាក្សាហ្នឹងមានចម្រូងចម្រាសម្ដងហើយម្ដងទៀត ។

បញ្ហាដំបូងនេះ គឺអង្គជំនុំជម្រះសុំស្នើទៅមេធាវីការពារជនជាប់ចោទថា ឲ្យទទួលនូវភាពជំនាញរបស់ ក្រេក អេតធេសាន់ ក្នុងការធ្វើការរបាយការណ៍ដែលបានលើកឡើងមក ដែលគាត់បានធ្វើរបាយការណ៍ជូនអង្គជំនុំជម្រះ អង្គសវនាការប៉ុន្មានថ្ងៃមកនេះ ។ នេះជាបញ្ហាទីមួយ តើខាងមេធាវីការពារជនជាប់ចោទហ្នឹង មានយោបល់យ៉ាងម៉េចដែរលើបញ្ហានេះ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រហែលជាដើម្បីបញ្ជាក់ឲ្យច្បាស់អំពីគោលបំណងនៃសំណួរនេះ យើងខ្ញុំចង់ដឹងថា តើខាងមេធាវីការពារក្ដីមានគោលបំណង និងធ្វើការជំទាស់ ឬក៏លើកឡើងអំពីជំនាញរបស់ ក្រេក អេតធេសាន់ ដែរឬអត់? ឬមួយថាតើមេធាវីការពារក្ដីព្រមទទួលសម្គាល់ថាតើ ថាគាត់គឺមានសមត្ថភាពគ្រប់គ្រាន់ដើម្បីឲ្យគាត់ធ្វើការវិភាគទៅលើប្រធានបទដែលគាត់បានធ្វើឡើងនៅក្នុងរបាយការណ៍របស់គាត់ ។

[០៩:៣៤:១៩]

**លោក ការ សាវុត្ថ៖**

សូមគោរព លោកប្រធាន! យើងខ្ញុំជាមេធាវីការពារ យើងខ្ញុំសុំទទួលសម្គាល់ចំពោះជំនាញរបស់លោកបណ្ឌិត ក្រេក អេតធេសាន់ ។ សូមអរគុណ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ក៏ប៉ុន្តែអ្វីដែលយើងបានលើកឡើងនេះ គឺមិនអាចខាឃាំងយើងឲ្យយើងធ្វើការអង្កេតថាគាត់ហ្នឹងគឺជាសមាជិកម្នាក់នៃការិយាល័យសហព្រះរាជអាជ្ញានោះទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ លោកប្រធាន ។

លោក ហ្វ្រង់ស្វ័រ រូ ទាក់ទងទៅនឹងការអង្កេតដែលថាគាត់ហ្នឹងជាសមាជិកម្នាក់របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយនឹងអ្វីដែលលោកបាននិយាយទាក់ទងទៅនឹងរបាយការណ៍របស់គាត់ហ្នឹង គឺដូចជាស្នើមកឲ្យខាងអង្គសវនាការនេះ ហើយលោកមានមន្ទិលសង្ស័យទៅលើជំនាញរបស់គាត់ ។ យើងចង់បានចម្លើយឲ្យបានច្បាស់លាស់ថា លោកហ្នឹងមិនធ្វើការប្រលឹម ឬក៏ជំទាស់ទៅនឹងអ្វីដែលគាត់បានសរសេរនៅក្នុងរបាយការណ៍គាត់នោះ ។ នេះគឺជាបញ្ហាដែលតាមខ្ញុំយល់ ដែលខាងសហព្រះរាជអាជ្ញា បានមានប្រតិកម្មចំពោះចំណុចនេះ ។ អ្វីដែលយើងចង់បាននោះ គឺចង់រកនូវដំណោះស្រាយមួយដើម្បីជំរុញឲ្យយើងធ្វើដំណើរការទៅមុខ ដើម្បីឲ្យមានដំណើរការសវនាការហ្នឹងឯង គឺវាមានតម្លាភាពមានយុត្តិធម៌ ហើយនិងជឿនលឿនទៅមុខ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ការពិតដែលថា លោក ក្រេក អេតធេសាន់ គឺជាផ្នែកនៃការិយាល័យសហព្រះរាជអាជ្ញា គឺជាធាតុផ្សំមួយដែលអាចជំទាស់បាន ក៏ប៉ុន្តែអ្វីដែលយើងចង់ដឹងនោះ គឺថាតើលោកយល់ថាមកពីមូលហេតុនេះឬ? ដែលគុណភាព ឬក៏លក្ខណៈសម្បត្តិរបស់លោក ក្រេក អេតធេសាន់ ក្នុងលក្ខណៈជាជំនាញហ្នឹង អាចនឹងត្រូវបានសួរបញ្ជាក់បន្ថែម ឬមួយក៏លោកមានចំណុចអ្វីមួយដែលអាចបញ្ជាក់អំពីលទ្ធផលទៅមុខរបស់គាត់ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោក ការ សាវុត្ថ បានឆ្លើយច្បាស់ហើយ គឺថាយើងទទួលយកនូវជំនាញរបស់គាត់ ប៉ុន្តែលោកក៏គួរតែត្រូវបានរំឭកផងដែរថា ទាក់ទងទៅនឹងគោលបំណងជំទាស់របស់យើងនោះ ។ គាត់គឺជាសមាជិកមួយនៃការិយាល័យសហព្រះរាជអាជ្ញា ប៉ុន្តែខ្ញុំមិនដឹងជានិយាយអ្វីបញ្ជាក់ឲ្យបានច្បាស់ទេ គឺយើងព្រមទទួលយកភាពជំនាញរបស់គាត់ ប៉ុន្តែអ្វីដែលគាត់និយាយក៏ដោយ គឺថាជាការច្បាស់ណាស់ គាត់គឺជា

ផ្នែកមួយនៃការិយាល័យសហព្រះរាជអាជ្ញា ។

ដូច្នេះហើយ យើងនឹងពិនិត្យមើលរបស់គាត់ក្នុងនាមគាត់ជាជំនាញ ក៏ប៉ុន្តែក៏ជាផ្នែកមួយនៃការិយាល័យសហព្រះរាជអាជ្ញាដែរ ។ ប៉ុន្តែ យើងមិនជំទាស់ទៅនឹងភាពជំនាញរបស់គាត់ទេ ខ្ញុំសូមបញ្ជាក់ម្តងទៀត គឺថាគាត់បានមានជីវិតជាអ្នកជំនាញ ជាបញ្ញវន្ត ដូច្នេះយើងបានទទួលសម្គាល់ថា គាត់ជាអ្នកជំនាញ ។

[០៩:៣៨:៣០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះដើម្បីឲ្យយើងកាន់តែប្រាកដជាងនេះ ដើម្បីឲ្យយើងយល់ដឹងជាងនេះ ខ្ញុំសូមសួរម្តងទៀត។ ថាតើអង្គហេតុនៃការជំទាស់ដែលថា លោក ក្រេក អេតឆេសាន់ គឺជាផ្នែកមួយនៃការិយាល័យសហព្រះរាជអាជ្ញានោះ? តើគាត់នឹងមានជាឥទ្ធិពល ឬក៏មានឥទ្ធិពលអ្វីទៅលើគុណភាពនៃការវិភាគរបស់គាត់ដែរឬទេ? ថាតើលោកគិតថា ចំណុចនេះនឹងអាចបណ្តាលឲ្យមាន ឬក៏នាំទៅរកៗឲ្យមានភាពលម្អៀងនោះដែរឬទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំសុំទោស ខ្ញុំសូមលោកកុំសួរខាងក្រោមមេធាវីការពារក្តីថានេះ គឺជារឿងដូចគ្នានោះ ។ ករណីដូចជាលោក ដេវីដ ឆេនល័រ ដែលជាអ្នកជំនាញ ដែលជាជនឯករាជ្យដែលមិនស្ថិតនៅក្រោមការិយាល័យសហព្រះរាជអាជ្ញា ប៉ុន្តែលោក ក្រេក អេតឆេសាន់ គាត់ក៏ជាអ្នកជំនាញ ប៉ុន្តែជាអ្នកជំនាញដែលធ្វើការជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ហើយចំណុចនេះគឺមិនដូចគ្នាទេ គឺថាគាត់មិនដូចជាជំនាញ ដេវីដ ឆេនល័រ ទេ ។ ពីព្រោះ ដេវីដ ឆេនល័រ គឺជាអ្នកជំនាញខាងមេធាវីការពារក្តីស្នើឲ្យគាត់ឡើងមក ។ ហើយចំណែកលោក រ៉ោល ចេនណឺ ហ្នឹងឯង គឺមេធាវីការពារក្តីបានឲ្យគាត់ៗមកបម្រើការពីរបីខែ ដើម្បីបំពេញនូវការវិភាគរបស់គាត់ ។ ប៉ុន្តែ គាត់គឺមិនជាផ្នែកមួយ ជាបុគ្គលិករបស់មេធាវីការពារក្តីទេ ។

អ៊ីចឹងមានន័យថា បុគ្គលិកជំនាញទាំងបីនាក់នេះ គឺថាពួកគាត់ហ្នឹងមិនមែនមានឋានៈដូចគ្នានោះទេ ពីព្រោះពួកគេគាត់មានតួនាទីផ្សេងៗគ្នា ។ ដូចជា លោក ដេវីដ ឆេនល័រ គឺគាត់នៅខាងក្រៅនៃទិវិថេតរបស់យើង ។ ចំណែកលោក រ៉ោល ចេនណឺ គឺបានមកធ្វើការជាទីប្រឹក្សាឲ្យខាងមេធាវីការពារក្តី ។ ចំណែកលោក ក្រេក អេតឆេសាន់ គឺជាមន្ត្រី គឺជាសមាជិកនៃការិយាល័យសហព្រះរាជអាជ្ញា ។

ដូច្នេះពួកគេមានតួនាទីផ្សេងៗគ្នា ក៏ប៉ុន្តែយើងបានទទួលស្គាល់នូវគុណភាពរបស់គាត់នៅក្នុងនាមគាត់ជាជំនាញ ។ ហើយខ្ញុំមិនដឹងជានិយាយអ្វីផ្សេងឲ្យបានច្បាស់ជាងនេះទៀតទេ ។

[០៩:៤១:០៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ថាតើមានផ្នែកណាមួយនៅក្នុងរបាយការណ៍របស់ជំនាញ ដែលលោកគិតថា វាជាបញ្ហាសត្យានុម័តដោយយើងផ្អែកទៅលើគុណសម្បត្តិដែលយើងថា គាត់ជាបុគ្គលិករបស់សហព្រះរាជអាជ្ញា? ប៉ុន្តែថាតើវាជាក់ស្តែងយ៉ាងម៉េចថា វាប៉ះពាល់យ៉ាងម៉េច ទៅលើគុណភាពនៃវិភាគរបស់គាត់?

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

ជាពិតណាស់ ។ សូមឲ្យយឺតបន្តិចសម្រាប់អ្នកបកប្រែ ។ ជាការពិត ខ្ញុំអាចធ្វើបែងចែកអំពីដំណាក់កាលពីរខុសគ្នា ។ ខ្ញុំសូមនិយាយថា របាយការណ៍ដែលបានដាក់ដោយលោក ក្រេក អេតឆេសាន់ នៅក្នុងខែកក្កដា ឆ្នាំ២០០៧ គឺដែលពេលនោះជនជាប់ចោទ មិនទាន់បានបង្ហាញនូវនៅក្នុងអង្គសវនាការរបស់យើងនោះទេ ។ ដូច្នេះហើយ វាជាបញ្ហាអត្តនោម័តទៅលើករណីនេះ ហើយយើងមិនអាចចោទសួរបាននៅពេលនេះ នៅពេលដែល ឌុច ត្រូវបានចាប់ខ្លួន ។ បន្ទាប់មកលោក អេតឆេសាន់ ជួយការងារសហព្រះរាជអាជ្ញាក្នុងការផ្តល់ភស្តុតាងប្រឆាំងទៅលើ ឌុច ។ ហើយចំណុចនេះ គឺវាបង្ហាញយ៉ាងច្បាស់នៅក្នុងការចោទសួរទៅកាន់លោក ក្រេក អេតឆេសាន់ ហួសពីរបាយការណ៍របស់គាត់ដែលគាត់បានសរសេរ ។

លោកចៅក្រម ឡាវែន៍ ប្រសិនបើយើងផ្តោតទៅលើរបាយការណ៍ដំបូងរបស់លោក ក្រេក អេតឆេសាន់ យើងអត់មានបញ្ហានោះទេ ប៉ុន្តែយើងតាំងសំណួរទៅកាន់គាត់ចំពោះធាតុផ្សំមួយចំនួន វាបញ្ហាមានកំហុស ដោយសារតែគាត់ចូលរួមនៅក្នុងដំណើរការស៊ើបអង្កេត ។ ដូច្នេះ កុំជម្រាបខ្ញុំថា គាត់មិនភាពលម្អៀងគឺគាត់មានការជួយទៅដល់ការងារសហព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ ដូច្នេះហើយវាបង្ហាញយើងច្បាស់ទៅលើចំណុចនេះ ។

ដូច្នេះ នៅពេលនេះយើងគ្មានសវនាការជាអសាធារណៈ ។ ខ្ញុំជឿថា វាជាកំហុសមួយខាងសហព្រះរាជអាជ្ញា ដែលយកអ្នកជំនាញជាបុគ្គលមួយនៅក្នុងក្រុមរបស់គាត់ ។ ដូច្នេះហើយវាជាចំណុចខុសមួយ ។ ដូច្នេះ សហព្រះរាជអាជ្ញា មិនគួរធ្វើដូច្នេះនោះទេ ។ ហើយប្រសិនយើងផ្អែកទៅលើរបាយការណ៍ចុះខែកក្កដា ឆ្នាំ២០០៧ នោះ ខាងមេធាវីការពារក្តីមិនជំទាស់ទេ ។ នេះគឺជាចំណុចកម្រិតចំពោះ

យើងខ្ញុំ ។ ដូច្នេះ សូមឲ្យលោក ក្រេក អេតធេសាន់ កុំផ្តល់សក្ខីកម្មលើគ្រប់ករណីដែលគាត់បានដឹងបន្ទាប់ពីខែកក្កដា ឆ្នាំ២០០៧ ។ ខ្ញុំសង្ឃឹមថា នេះគឺជាចំណុចដែលថាយើងព្រមព្រៀងគ្នាបាន ។

[០៩:៤៥:៣៣]

**ប្រធានអង្គជំនុំ៖**

លោកស្រីចៅក្រម ខាតវាយថ៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ លោកប្រធាន ។

ប្រហែលវាជាភាពចាំបាច់ក្នុងការលើកឡើងសំណើពេញលេញតែម្តង ដែលអង្គសវនាការចង់ឲ្យភាគីធ្វើការពិចារណា ។ ការសម្បទានត្រូវបានសុំពីខាងមេធាវីការពារក្តី ដោយសារតែនៅក្នុងការយល់ឃើញរបស់តុលាការ ។ ករណីដែលថា អ្នកជំនាញ គឺជាបុគ្គលិករបស់សហព្រះរាជអាជ្ញា គឺវានាំទៅដល់មកខាងសហព្រះរាជអាជ្ញា ក្នុងការសង្ខេបទៅលើឯកសារទៅលើរបាយការណ៍ ដើម្បីឲ្យអង្គសវនាការជឿថាគាត់ពិតជាអ្នកជំនាញ ។ ដូច្នេះ យើងខ្ញុំនឹងធ្វើការវិធី ស្វែងរកវិធីសាស្ត្រ ដើម្បីដោះស្រាយបញ្ហានេះ ហើយទោះបីជាអានសេចក្តីសង្ខេបនោះក៏ដោយ គាត់មិនចាំបាច់អាននូវលេខយោងវាក៏ចំណាយពេលច្រើនដែរ ចំពោះឯកសារសង្ខេបនោះ ។ ហើយអ្នកជំនាញគឺគាត់មានពេលវេលាគ្រប់ពេលក្នុងការមកចូលរួមសវនាការនៅគ្រប់ពេល ។ ដូច្នេះ យើងមិនឃើញភាពចាំបាច់ក្នុងការធ្វើដូច្នោះទាំងអស់នោះទេ ។ ដូច្នេះ ខ្ញុំគិតថា មេធាវីការពារក្តីនឹងយល់ស្របទៅលើបញ្ហាហ្នឹង ដោយសារតែខ្ញុំមានបញ្ហាហ្នឹងដោយសារតែខ្ញុំឃើញមានការតវ៉ាៗ ហើយតវ៉ាទៀត ហើយវាចំណាយពេលច្រើននៅក្នុងករណីនេះ ។ គោលបំណងរបស់យើងនោះ គឺថាប្រសិនបើមានការបញ្ជាក់ច្បាស់លាស់ទៅលើជំនាញរបស់លោក ក្រេក អេតធេសាន់ នៅក្នុងការសរសេររបាយការណ៍របស់គាត់ ។

ដូច្នេះ សហព្រះរាជអាជ្ញា គឺនឹងអញ្ជើញឲ្យអានសេចក្តីសង្ខេបបី ឬក៏បួននូវឯកសារនៅក្នុងរបាយការណ៍ ដោយផ្អែកទៅលើការយល់ឃើញរបស់សហព្រះរាជអាជ្ញា ចំពោះអង្គហេតុដែលពាក់ព័ន្ធសម្រាប់អង្គសវនាការក្នុងការសម្រេចនៅក្នុងនីតិវិធីរបស់យើង។ នេះជាទស្សនទានរបស់យើង ។ ប៉ុន្តែការទទួលស្គាល់ថាលោក អេតធេសាន់ ជាបុគ្គលិកមួយរបស់ខាងសហព្រះរាជអាជ្ញានោះ ហើយភ្ជាប់ជាមួយនឹងជំនាញរបស់គាត់នោះ ក្នុងចំណុចនេះវាហាក់ដូចជាការចោទប្រកាន់ទៅលើខាងសហព្រះរាជអាជ្ញា ។ ដូច្នេះ យើងត្រូវតែរកទៅលើដំណោះស្រាយ នេះជាទស្សនទានដែលយើងលើកឡើងនៅពេល

នេះ ។

ខ្ញុំនិយាយលឿនពេកឬក៏យ៉ាងម៉េច? ដូច្នេះ យើងចង់ឲ្យលើកឡើងយោបល់នេះដើម្បីធ្វើឲ្យជាសាធារណៈ ហើយយើងនឹងស្នើសុំខាងសហព្រះរាជអាជ្ញា ឲ្យធ្វើការសម្របសម្រួលទៅលើបញ្ហានេះ ។ នេះជាទស្សនទានដែលយើងអាចចូលរួមចែករំលែកនឹងសម្បទាន ហើយយើងនឹងរកវិធីណាដើម្បីឲ្យសវនាការរបស់យើងពន្លឿនទៅមុខ ហើយដំណើរការបានល្អផ្តល់ព័ត៌មានទៅដល់សាធារណជន ។ ដូច្នេះ តើវាអាចផ្តល់នូវដំណោះស្រាយនឹងបានបំភ្លឺដែរឬទេលោក រូ? ហើយថាតើមានចំណុចខ្វះចន្លោះនៅក្នុងការផ្តល់ហេតុផលនេះ ដែលលោកចង់លើកឡើង ឬក៏យ៉ាងម៉េច?

[០៩:៤៨:៤៩]

**លោក ហ្វ្រង់ស្វ័រ រូ៖**

ជាការពិតនេះគឺយល់វា ត្រូវនឹងការយល់ស្របដែលដូចដែលលោក ការ សាវុត្ត បានលើកឡើងផងដែរ ។ យើងទទួលស្គាល់របាយការណ៍ដែលមានលក្ខណៈជំនាញរបស់លោក អេតធេសាន់ ។ របាយការណ៍ជំនាញនេះគឺត្រូវបានរៀបចំឡើងរួចរាល់នៅក្នុងខែកក្កដា ឆ្នាំ២០០៧ ហើយប្រសិនបើលោក ក្រេក អេតធេសាន់ គឺត្រូវបានដេញដោលដោយផ្អែកទៅលើរបាយការណ៍មួយនេះ យើងគ្មានបញ្ហាជំទាស់ ឬក៏លើបញ្ហានេះឡើយ ។ ប៉ុន្តែ យើងមានបញ្ហាប្រសិនបើលោក ក្រេក អេតធេសាន់ ត្រូវបានសួរដេញដោលទៅលើអង្គហេតុក្រោយខែកក្កដា ឆ្នាំ២០០៧ មកទល់ពេលបច្ចុប្បន្ន ។ ហើយប្រសិនបើយើងបន្ថែមថា វាជាភស្តុតាងថ្មី ដូចខាងសហព្រះរាជអាជ្ញាចេញពីការស៊ើបអង្កេត ដូច្នេះខ្ញុំមិនចង់ឲ្យលោក ក្រេក អេតធេសាន់ ត្រូវបានតាំងសំណួរឬក៏ដេញដោលលើអង្គហេតុនៅក្នុងដំណាក់កាលស៊ើបអង្កេតដែលគាត់បានចូលរួមការងារនៅទីនោះទេ ។ នេះជាផលប្រយោជន៍ខាងសហព្រះរាជអាជ្ញា ។ ហើយចាប់ពីខែកក្កដា ឆ្នាំ២០០៧ នោះ គឺឃើញមានការស៊ើបអង្កេត ។ ហើយយើង ដូចដែលខ្ញុំបានលើកហើយ លោក ការ សាវុត្ត បានទទួលស្គាល់ទៅលើរបាយការណ៍ខែកក្កដា ឆ្នាំ២០០៧ ហើយយើងខ្ញុំមិនចង់ឲ្យលោក ក្រេក អេតធេសាន់ ធ្វើការនិយាយអំពីអង្គហេតុក្រោយនោះ ។ ដូច្នេះហើយ ដើម្បីធ្វើការគាំទ្រទៅលើបញ្ហានេះ គឺខ្ញុំយល់ឃើញថា យើងមិនគួរលើកអង្គហេតុក្រោយពេលនោះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា តើមានចង់លើកឡើងអំពីបញ្ហាអ្វីទេ?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណលោកប្រធាន ។ ខ្ញុំមានមូលហេតុពីរដែលខ្ញុំចង់សង្ខេបឯកសារនេះដាក់ជូនសវនាការនោះ ។ មូលហេតុទីមួយដែលខ្ញុំបានបញ្ជាក់នឹងកំណត់រួចហើយ ដោយសារតែវាហាក់ដូចបង្ហាញជូនសហព្រះរាជអាជ្ញា ទៅលើមន្ទិលសង្ស័យនៃភាពលម្អៀង ហើយនិងភាពជឿជាក់ទៅលើរបាយការណ៍របស់លោក ក្រេក អេតធេសាន់ ។ មូលហេតុទីពីរ គឺមិនទាន់មានការលើកឡើងទៅលើគោលការណ៍ចម្បងដែលថា លោក ក្រេក អេតធេសាន់ ចំពោះឯកសាររបស់គាត់នោះទេ ហើយគឺវាទាក់ទងទៅនឹងឯកសារផ្សេងៗដែលយើងដាក់ជូនអង្គសវនាការ ។ ឧទាហរណ៍ទៅលើការបង្កើតអង្គហេតុទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ ។ ដូច្នេះ យើងមិនឃើញមានសាក្សីណាមួយបានបង្កើតឯកសារទាំងអស់នោះ ។ ហើយចំពោះសេចក្តីសម្រេចកាលពីម្សិលមិញរបស់អង្គសវនាការ ដែលបានបំភ្លឺទៅលើវិធាន៨៧.២ និង ៣ គឺទាក់ទងទៅនឹងឯកសារដែលត្រូវអានពេញលេញ ឬក៏ជាសង្ខេបទើបយកមកផ្អែកជាសាលក្រម ។ ដូច្នេះហើយសហព្រះរាជអាជ្ញាគិតថា ឯកសារគួរតែអានដោយសារតែមូលហេតុនេះហើយទើបយើងខ្ញុំធ្វើការសង្ខេបថា តើយើងមានវិធីណាផ្សេងដែលថាយើង ត្រូវបង្ហាញអំពីរបាយ-ការណ៍របស់លោក ក្រេក អេតធេសាន់ ក្នុងការលើកឡើងអំពីការវាយប្រហារផ្សេងៗ ដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធ ។ ដោយយោងទៅតាមឯកសារទាំងអស់នោះហើយ ទើបយើងអាចបង្ហាញបាន ។

ខ្ញុំត្រូវតែនិយាយថា ជាការពិតណាស់ មិនសហការីរបស់ខ្ញុំ សហសេវិករបស់ខ្ញុំ រួមទាំងខ្ញុំគឺលើកឡើងទៅលើចំណុចនេះថា វាជាចំណុចសំខាន់ ។ ដូច្នេះហើយ គឺខ្ញុំនៅតែទទូច និងចង់ចំណាយពេលបន្តិច ឲ្យច្រើនបន្តិចទៅបញ្ហានៃឯកសារទាំងអស់នេះ ។ យើងបានទទួលសេចក្តីណែនាំថាតើការងារបង្ហាញឯកសារភស្តុតាងនេះធ្វើយ៉ាងម៉េច? ហើយយើងក៏បានធ្វើការទទូចសុំឲ្យធ្វើការពន្លឿនទៅលើសវនាការឲ្យបានលឿនផងដែរ ។ ខ្ញុំលើកឡើងអំពីឯកសារទាក់ទងនឹងជម្លោះប្រដាប់អាវុធ ហើយខ្ញុំមិនមានឯកសារមកជាមួយនៅពេលនេះទេ ប៉ុន្តែខ្ញុំជឿថាមានរាប់រយទាក់ទងទៅនឹងឯកសារនេះ ។

ខ្ញុំទទួលព័ត៌មានថា មានឯកសារបីទៅបួនរយឯណោះទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធនោះ ។ ហើយទាក់ទងទៅនឹងសេចក្តីសម្រេចកាលពីម្សិលមិញ ចំពោះខាងសហព្រះរាជអាជ្ញាវាមានន័យថាឯកសារនីមួយៗទាំងអស់នោះគឺទាមទារឲ្យមានការអាននិងធ្វើការអានដោយសង្ខេប ។ ប៉ុន្តែ ជាអកុសលយើងអត់មានអ្នកជំនាញណាមួយដែលបង្កើតឯកសារទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធនោះទេ ។

ដូច្នេះ ខ្ញុំនិយាយជាក់លាក់ទៅលើរបាយការណ៍សារព័ត៌មានអំពីទូរលេខផ្សេងៗ និងប្រភព

ផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ។ យើងឃើញមានពីរចំណុចដែលថា ដែលយើងសង្ខេបនៅទីនេះ ។

ទាក់ទងទៅនឹងលោក ក្រេក អេតឆេសាន់ សហព្រះរាជអាជ្ញាពិចារណាឃើញថា វិធីសាស្ត្រដែលខាងមេធាវីការពារក្តីឆ្លើយតបនោះ គឺលើកឡើងថា មានភាពសង្ស័យទៅលើភាពអព្យាក្រឹតរបស់អ្នកជំនាញ ។ ខាងអង្គសវនាការបានសម្រេចហើយថា ភាគីណាក៏ដោយគឺមិនអាចកម្រិតទៅលើការតាំងសំណួរទៅកាន់អ្នកជំនាញនោះទេ ។ ហើយអង្គសវនាការមានសេរីភាពក្នុងការតាំងសំណួរទៅកាន់អ្នកជំនាញ ប្រសិនបើយល់ឃើញថាត្រឹមត្រូវ ។ ដោយសារចំណុចនោះ ហើយវាជាចំណុចមួយសមហេតុផល ចំពោះការទាញសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ ។ ខ្ញុំឃើញមានបញ្ហាធំជាងនេះចំពោះបញ្ហាដែលយើងចង់ដាក់ជូនអង្គសវនាការ ។ ហើយយើងខ្ញុំសង្ឃឹមថា យើងគួរតែមានវិធីសាស្ត្រណាមួយក្នុងការធ្វើដូច្នេះឲ្យលឿនបំផុតដោយមិនចាំបាច់អានទៅលើឯកសារសង្ខេប ឬក៏អានទៅលើឯកសារដែលយើងយោង ។ ប្រសិនមិនដូច្នោះទេ យើងនឹងមិនមានឯកសារសម្រាប់ផ្អែកទៅលើសាលក្រម ឬក៏ចំណុចផ្សេងៗ នោះផងដែរ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ។

[០៩:៥៦:៣៨]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ លោកអាឡិច ចំពោះបញ្ហាដែលលោកលើកឡើង ទាក់ទងជម្លោះប្រដាប់អាវុធ ។ ខ្ញុំទទួលស្គាល់អំពីបញ្ហា ។ ជាបឋមជនជាប់ចោទ គាត់មិនបានទទួលស្គាល់ ដោយពេញលេញទៅលើអង្គហេតុទាក់ទងជម្លោះប្រដាប់អាវុធនោះទេ ។ ដូច្នេះហើយ អង្គហេតុនេះត្រូវតែបង្ហាញឲ្យឃើញវាជាគោលបំណងក្នុងការប្រើប្រាស់អ្នកជំនាញ របាយការណ៍អ្នកជំនាញ ណាយ៉ាន់ ចាន់ដា ដើម្បីពិនិត្យនៅចំពោះមុខអង្គសវនាការ។ ហើយឯកសារដែលគាត់ដឹងនោះ គឺយើងនឹងរកវិធីសាស្ត្រក្នុងការរៀបចំដាក់ឯកសារនៅចំពោះមុខអង្គសវនាការ ។ ហើយប្រសិនបើចាំបាច់នោះយើងនឹងធ្វើការកោះហៅលោក ក្រេក អេតឆេសាន់ សាជាថ្មី នេះជាបញ្ហាមួយ ។ បញ្ហាទីពីរគឺបញ្ហាទាក់ទងទៅនឹងអង្គសវនាការសាលាដំបូងរបស់យើង គឺយើងព្យាយាម លោកព្យាយាមដាក់នៅចំពោះមុខអង្គសវនាការ ដោយប្រើប្រាស់អ្នកជំនាញមួយនេះ ដែលវាទាក់ទងទៅនឹងឯកសារជាច្រើន ដោយឯកសារទាំងអស់នោះ វាមិនទាក់ទងទៅនឹងប្រធានបទគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងស-២១ ។ ដូច្នេះហើយ យើងព្យាយាមរក

វិធីណាមួយដែលយើងអាចជ្រើសរើសឯកសារទាំងអស់នោះ ហើយយើងអាចយល់ថាឯកសារទាំងអស់នោះ វាពាក់ព័ន្ធនៅក្នុងពេលដែលយើងយកមកដេញដោលក្នុងសវនាការ ដោយយើងគោរពទៅលើអង្គហេតុទាំងអស់នោះ ។ ដូច្នេះ ដូចដែលលោកបានឃើញហើយក្នុងការបំពេញចន្លោះប្រហោងហើយមេធាវីការពារក្តី ហើយនិងខាងដើមបណ្តឹងរដ្ឋប្បវេណីក៏យល់ឃើញដូចគ្នា ។ នៅក្នុងបញ្ហាអនុវត្តជាក់ស្តែងខ្ញុំសុំស្នើថា នៅពេលដែលលោកអាននូវសេចក្តីសង្ខេប គឺសេចក្តីសង្ខេបដែលលោកមាននៅក្នុងដៃនោះ លោកមិនចាំបាច់អានលេខ ERN នោះទេ ។ លោកអាចអានអំពីទំព័រ ចំណងជើង ឬក៏ឈ្មោះផ្សេងៗទៅបានហើយ ។ នេះជាការស្នើសុំចំពោះការអានឯកសារទៅដល់ភាគី ។ ដូច្នេះ លោកអាចជ្រើសរើសឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះដើម្បីយើងបំពេញចន្លោះប្រហោង ហើយយើងនឹងប្រើប្រាស់ឯកសារពាក់ព័ន្ធនៅពេលក្រោយទៅទៀត ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

ខ្ញុំមិនចង់ធ្វើការសន្យាអំពីចំណុចនេះទេ ។ នៅពេលនេះ ចាំខ្ញុំទទួលយកនូវការណែនាំពីប្រធានរបស់ខ្ញុំសិន ។ បើអ៊ីចឹងប្រហែលជាលោក លោកស្រីយល់ដឹងអំពីពេលវេលាដ៏ខ្លីដែលយើងមាននេះហើយ។

[១០:០០:០០]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ចំណុចមួយទៀត ដែលខ្ញុំចង់និយាយហ្នឹងគឺថា អង្គជំនុំជម្រះនឹងគិតយល់អំពីបញ្ហាបញ្ញត្តិមួយចំនួន ដែលធ្វើការពិនិត្យយ៉ាងយកចិត្តទុកដាក់ បើសិនជាអាចជួយយើងបាននៅក្នុងពេលអនាគត ។ ប៉ុន្តែគឺថាយើងមានបញ្ហាបឋមនៅចំពោះមុខនេះ ហើយយើងមិនប្រាកដថាតើសេចក្តីសម្រេចរបស់ *អាយស៊ីស៊ី* នោះដែលអាស្រ័យទៅលើ ខមិនឡូ ហ្នឹងអាចយកមកត្រូវប្រើប្រាស់បាន ឬក៏បាននោះទេ ប៉ុន្តែគឺថាយើងគំនិតដូច្នេះ ។ តើយើងមិនអាចយកមកធ្វើអ្វីកើតទេរហូតដល់ខែកញ្ញា ឯណោះ ។ យើងយើងសង្ឃឹមថានៅពេលនុំងឯង គឺសេចក្តីសក្ខីកម្ម នោះឯងបានបញ្ចប់រួចទៅហើយ ។ បើយើងគំនិតទៅលើរឿងនេះ ប៉ុន្តែគឺមិនអាចធ្វើបានទេ នៅពេលនេះ ។ ដូច្នេះ ប្រហែលជាលោកអាចផ្តល់អនុសាសន៍ទៅខាងប្រធានរបស់លោកថា នេះគឺអ្វីដែលខាងអង្គជំនុំជម្រះហ្នឹងឯងយល់ថា គឺជាការបង្រួបបង្រួមមួយ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

ខ្ញុំចង់សូមធ្វើការអង្កេតមួយ ប្រសិនបើខ្ញុំអាចធ្វើការអង្កេតមួយនោះ ដើម្បីឲ្យបានយល់អំពីអ្វី

ដែលលោកស្រីចៅក្រម ទើបតែបានពន្យល់ គឺដូចជាការបង្ហាញថា ខាងអង្គជំនុំជម្រះហ្នឹងបានស្នើថា គឺអាស្រ័យទៅតាមករណីនីមួយៗ គឺយើងពិនិត្យមើលទៅលើឯកសារដ៏ច្រើនដែលជាបញ្ហានោះ ហើយនឹងត្រូវសម្រេចថាតើ បញ្ហានីមួយៗនឹងត្រូវដោះស្រាយយ៉ាងម៉េច ឬក៏បង្ហាញយ៉ាងម៉េច? មានន័យថា គឺមិនមែនជាវិធានទូទៅ ដែលត្រូវយកមកអនុវត្តទៅលើបញ្ហានោះទេ ។ ប៉ុន្តែ នេះគឺជាវិធីមួយដើម្បីដោះស្រាយទៅតាមបញ្ហានីមួយៗ ។ ឧទាហរណ៍បញ្ហាជម្លោះប្រដាប់អាវុធអន្តរជាតិហ្នឹង អាចជាបញ្ហាស្មុគស្មាញ តើនេះជាអ្វីដែលខ្ញុំយល់ច្បាស់អំពីការពន្យល់របស់លោកស្រីចៅក្រមទេ?

[១០:០២:០០]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ទៅតាមការយល់ដឹងរបស់ខ្ញុំទៅលើប្រព័ន្ធស៊ីវិលឡូគឺថា យើងមានលទ្ធភាពក្នុងការអាន ឬក៏ធ្វើសេចក្តីសង្ខេបឯកសារណាមួយ ។ ដូច្នេះហើយ នៅចុងបញ្ចប់នៃសវនាការ ប្រសិនបើខាងសហព្រះរាជអាជ្ញា ឬក៏ភាគីណាមួយយល់ថានៅមានចន្លោះនោះ អ៊ីចឹងគឺថា យើងអាចធ្វើបាននៅពេលនោះ ។ តើនេះជាការយល់ដឹងត្រឹមត្រូវរបស់ខ្ញុំទេ? មានន័យថា យើងមិនចាំបាច់ដាក់ឯកសារដ៏ច្រើននៅតាមចំណុចណាមួយនៅក្នុងអំឡុងពេលណាមួយនៃសវនាការនោះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បើនេះជាប្រហែលជាទស្សនៈផ្ទាល់ខ្លួន ប៉ុន្តែ ខ្ញុំក្នុងនាមជាចៅក្រម នៅក្នុងប្រព័ន្ធស៊ីវិលឡូ នៅពេលដែលយើងចង់ដាក់ឯកសារអ្វីមួយនៅចំពោះមុខអង្គសវនាការ ឯកសារនោះត្រូវធ្វើការវាយតម្លៃដោយចៅក្រម ឬក៏ចៅក្រមច្រើននាក់ តាមរយៈការសួរដេញដោល ។ ហើយនៅក្នុងឧទាហរណ៍របស់លោកក្នុងករណីឯកសារចំនួន១៤៨ ដែលលោកបាននិយាយ ដែលលោកចង់បង្ហាញនៅចំពោះមុខអង្គសវនាការនោះ ខ្ញុំយល់ថា ប្រហែលជាម្ភៃប៉ុណ្ណោះ គឺត្រូវបានបកប្រែជាភាសាបារាំង ។ ហើយក្នុងករណីខ្ញុំជាចៅក្រម និយាយភាសាបារាំង ហើយនិងជាសមាជិកនៃចៅក្រមនេះ ខ្ញុំមានការលំបាកមួយចំនួន ។ ហើយជាការពិតណាស់ដែរ ដែលថាសម្រាប់ឯកសារនីមួយៗ ប្រសិនបើយើងអាចធ្វើទៅរួចនោះ គឺវាអាចលើសពីអ្វីដែលជាជំនាញរបស់លោក គ្រេក អេតឆេសាន់ ហើយយើងអាចមានសំណួរមួយចំនួនទាក់ទងទៅនឹងការទទួលខុសត្រូវនីមួយៗ ឬទៅលើប្រជាជន ឬក៏មនុស្ស ដែលត្រូវបានចោទ

ប្រកាន់នៅក្នុងសំណុំរឿងផ្សេងៗទៀត ឬក៏អ្នកដែលជាជនសង្ស័យ ។ ដូច្នេះ ចំណុចនេះអាចបណ្តាលឲ្យមានការលើកឡើងនូវសំណួរមួយទៀត អំពីការប្រព្រឹត្តិទៅបានល្អនៃតុលាការ នៃប្រព័ន្ធយុត្តិធម៌ ។ បើនឹងមានឯកសារ និងសម្ភារៈមួយចំនួន ដែលនឹងត្រូវពិនិត្យមើលផ្សេងៗដាច់ពីគ្នា ដែលត្រូវការឲ្យមានការពិភាក្សាដេញដោល ហើយគឺថា អាចនឹងធ្វើឲ្យពន្យារពេលដំណើរការសវនាការនេះជាច្រើនខែបានយ៉ាងស្រួល ។ នេះគឺជាសេចក្តីបារម្ភផ្ទាល់ខ្លួនរបស់ខ្ញុំ ។

**លោក ហ្វេង់ស្វ័រ រូ៖**

លោកប្រធាន, ខ្ញុំចង់និយាយអំពីវិធាននៃនីតិវិធីជាថ្មីម្តងទៀត ។ យើងបានពិចារណាទៅលើដីកាដំណោះស្រាយដែលបានប្រគល់ដល់អង្គសវនាការ ។ ហើយនៅពេលនេះ ខ្ញុំចង់ត្រឹមតែនិយាយអំពីលោក ក្រេក អេតឆេសាន់ នៅខែកក្កដា ឆ្នាំ២០០៧ គឺរបាយការណ៍របស់គាត់ នៅខែកក្កដា ឆ្នាំ២០០៧នោះ ។ តាមអ្វីដែលខ្ញុំយល់ គឺថារបាយការណ៍នេះ ឋិតនៅក្នុងកថាខណ្ឌទី១០ ទៅ ១៩ នៃដីកាដំណោះស្រាយ ។ ហើយមានតែប៉ុណ្ណឹងទេ ។

ខ្ញុំសុំនិយាយឡើងវិញម្តងទៀត សហចៅក្រមស៊ើបអង្កេតបានវិភាគទៅលើបរិបទប្រវត្តិសាស្ត្រ និងនយោបាយនៃបក្សកុម្មុយនីស្តកម្ពុជានៃកម្ពុជាប្រជាធិបតេយ្យ ។ ហើយសម្រាប់ហេតុផលនេះ គឺពួកគេបានបន្ថែម *ហ្វូតណូត* ហ្នឹងចំនួន៣០ទៀត ហើយមិនមាននរណាគេធ្វើការតវ៉ាទៅលើ *ហ្វូតណូត* នោះទេ ។ ហើយនេះឯងគឺជាផ្នែកមួយនៃសំណុំរឿងផងដែរ ។

[១០:០៦:៣៥]

ហើយប្រសិនបើលោក ក្រេក អេតឆេសាន់ ត្រូវធ្វើផ្តល់ការគាំទ្រទៅលើអ្វីដែលសហចៅក្រមស៊ើបអង្កេតបានធ្វើការងាររួចមកហើយនោះទេ? បាទ, គឺជាចំណុចត្រឹមត្រូវណាស់ ។ ប៉ុន្តែថាតើជាការចាំបាច់ទេ ក្នុងការបន្ថែមឯកសារជាច្រើនសន្លឹកសន្ធាប់នោះ តើមានអ្វីដែលជាគោលបំណងនោះ? បាទ, ដើម្បីកំណត់ឲ្យបានច្បាស់លាស់ ។ នេះគឺជាអត្ថប្រយោជន៍មួយនៅក្នុងប្រព័ន្ធខំមិនឡ ដែលខ្ញុំទទួលស្គាល់នូវអត្ថប្រយោជន៍នៃប្រព័ន្ធនេះ ។

ដូច្នេះ ដើម្បីកំណត់ឲ្យបានច្បាស់ យើងគួរតែធ្វើទៅតាមសំណើ ដែលចៅក្រម ខាតវ៉ាយថ៍ បានលើកឡើង ហើយសូមស្នើឲ្យខាងសហព្រះរាជអាជ្ញាធ្វើការសួរបន្ថែមទៀតទៅលើលោក ក្រេក អេតឆេសាន់ ដែលលោកត្រូវបានគេ លោក លោកស្រីចៅក្រមសម្ភាសន៍ជាច្រើនដងរួចមកហើយ ។ ហើយសូមកុំឲ្យ សហព្រះរាជអាជ្ញាហ្នឹងសួរសំណួរទៅលើលោក ក្រេក អេតឆេសាន់ ។ ហើយបើសិនជា

សំណួរមួយ ឬក៏សំណួរណាមួយទៀត ពីព្រោះអីបើសិនជាសំណួរអស់ទាំងហ្នឹង គឺអាស្រ័យទៅលើឯកសារចំនួន១៤០ជាងនោះ ពេលនុំ៎ងឯង គឺលោក ក្រេក អេតធេសាន់ អាចនឹងបង្ហាញឯកសារហ្នឹងដល់អង្គសវនាការ ឬក៏អាចធ្វើសេចក្ដីសង្ខេបពីឯកសារហ្នឹងបាន ។ ហើយទស្សនៈរបស់ខ្ញុំគឺថា លោក អេតធេសាន់ បានពន្យល់គ្រប់គ្រាន់ហើយ ។ ហើយអ៊ីចឹងនៅពេលដែលមានចំណុចណាដែលគួរបញ្ជាក់ ទើបឯកសារហ្នឹងត្រូវបានដកស្រង់ចេញ ដើម្បីបង្ហាញពីអ្វីដែលលោក អេតធេសាន់ បាននិយាយដោយយោងទៅលើឯកសារនោះ ។ ហើយគឺថា យើងមិនត្រូវការឯកសារទាំង១៤៨ នោះទេ ។

ជាថ្មីម្ដងទៀត ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រម នៅចាំថា គឺថាកថាខណ្ឌទី១០ ដល់ទី ១៩ នៃដីកាដំណោះស្រាយ ដែលបានរៀបរាប់យ៉ាងច្បាស់លាស់នូវប្រវត្តិនយោបាយ និងប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យ ហើយខាងសហព្រះរាជអាជ្ញាមិនបានលើកអំពីចំណុចនេះទេ ហើយក៏មិនបានតវ៉ាដែរ ហើយខាងមេធាវីការក្ដីក៏មិនបានតវ៉ាអ្វីទៅលើចំណុចនេះដែរ ហើយក៏មិនមានការតវ៉ាទៅលើ *ហ្វូតណូត* ១ ដល់ ៣០ ផងដែរ ដែលមានភ្ជាប់នៅជាមួយរបាយការណ៍នោះ ។ មានន័យថា អ្វីដែលធ្វើហ្នឹងគឺចៀសវាង ការខាតបង់ពេលវេលា ។

[១០:០៩:៥០]

**លោកស្រី វ៉ាបេសាន់ដ្រាតាណា៖**

ខ្ញុំសូមថ្លែងមតិយោបល់របស់ខ្ញុំបន្តិច ។ សូមអរគុណលោកប្រធាន ។

ខ្ញុំមានសេចក្ដីសន្និដ្ឋានពីរដែលខ្ញុំចង់ដាក់ក្នុងនាមខ្ញុំជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។ ទីមួយទាក់ទងទៅនឹងស្ថានភាពរបស់ជនរងគ្រោះនៅចំពោះមុខតុលាការរបស់លោក ។ ជនរងគ្រោះនេះ គឺវាផ្សេងគ្នាពីតុលាការ ពីស្ថានភាពរបស់ជនរងគ្រោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយខ្ញុំជាមេធាវីរបស់តុលាការនោះ ហើយនៅក្នុងតុលាការនោះ គឺថាជនរងគ្រោះអាចបង្ហាញអំពីការអង្កេតរបស់ខ្លួនបាន ។ ប៉ុន្តែនៅទីនេះ ស្ថានភាពជនរងគ្រោះ គឺមានឥទ្ធិពលផ្ទាល់ ។ ខ្ញុំយោងទៅលើវិធាន២៣ គឺថាជនរងគ្រោះគឺជាភាគីនៃដំណើរការនីតិវិធី ។ ហើយខ្ញុំចង់និយាយអំពីចំណុចនេះដែរ ទាក់ទងទៅនឹងសវនាការអសាធារណៈនោះ ។ បើសិនជាយើងជាភាគីនៃនីតិវិធី មានន័យថា យើងមានសមត្ថភាពដូចគ្នាទៅនឹងខាងសហព្រះរាជអាជ្ញានិងមេធាវីការពារក្ដីផងដែរ ។ ដូច្នេះ នៅក្នុងករណីនេះ គឺថាសវនាការសាធារណៈ មិនត្រូវបានយកមកអនុវត្តទេ ។ មានន័យថា គឺថានៅក្នុងសវនាការអសាធារណៈគឺតុលាការអាចរក្សានូវអត្តសញ្ញាណរបស់ជនរងគ្រោះ នេះគឺជាចំណុចទីមួយ ។ ហើយចំណុចទីពីរ ដែលខ្ញុំចង់

លើកនោះ គឺថាភាពផ្សេងគ្នាដែលខាងមេធាវីការពារក្ដីបានលើកឡើងរវាងរបាយការណ៍ដែលអាចទទួលយកបាន គឺរបាយការណ៍កាលពីខែកក្កដា ឆ្នាំ២០០៧ និងអ្វីដែលកើតពេលក្រោយដែលមេធាវីការពារក្ដីមិនចង់ទទួលយកនោះ ។ អ៊ីចឹង បើសិនជានិយាយអំពីស្ថានភាពរបស់ជនរងគ្រោះវិញ មិនមានន័យថាជនរងគ្រោះមិនមានអ្វីដែលជាទំនាក់ទំនងជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ដូចដែលខាងមេធាវីការពារក្ដីបានលើកឡើងទេ ហើយក៏មិនមែននាំទៅរកឲ្យមានការលម្អៀងដែរ ។

[១០:១២:០៦]

ហើយទាក់ទងទៅនឹងវិធាន៣១ ខ្ញុំក៏សូមនិយាយឡើងថា ស្ថានភាពនេះ គឺនឹងអាចកើតមាននៅពេលដែលមានការយោងទៅលើអ្នកជំនាញ ដូចដែលមានចែងនៅក្នុងវិធាន៣១.៦ ដែលនិយាយថា ប្រសិនបើជាការចាំបាច់ក្នុងការបំពេញបេសកកម្មរបស់ខ្លួន អ្នកជំនាញអាចចូលរួមស្ដាប់ចម្លើយសាក្សី ឬជនត្រូវចោទ ឬជនជាប់ចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានសួរចម្លើយដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ។ ក្នុងករណីចាំបាច់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចអនុញ្ញាតឲ្យអ្នកជំនាញធ្វើសម្ភាសន៍ដោយផ្ទាល់ជាមួយសាក្សី ជនត្រូវចោទ ឬជនជាប់ចោទ នៅចំពោះមុខមេធាវីរបស់ពួកគេ ។ ហើយនៅខាងក្រោមមកទៀត គេបាននិយាយដែរ នៅក្នុងកថាខណ្ឌទី៨ អ្នកជំនាញត្រូវប្រគល់របាយការណ៍ ហើយនិងត្រូវដាក់បញ្ចូលនៅក្នុងសំណុំរឿង ។ នៅក្នុងការធ្វើសេចក្ដីព្រាងទៅលើវិធាននេះ គឺថារបាយការណ៍របស់អ្នកជំនាញ គឺចេញមកពីអ្នកជំនាញដែលជាអ្នកជំនាញឯករាជ្យ ដែលក្រោយមកគាត់បានចូលរួមនៅក្នុងសកម្មភាពរបស់ខាងសហព្រះរាជអាជ្ញា ។ ថាតើខាងដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏ជនជាប់ចោទ ឬក៏យ៉ាងម៉េចនោះ ហើយនៅពេលដែលមានកំណត់ហេតុលើកទៅលើនីតិវិធីនោះ គឺវាទាក់ទងទៅនឹងរបាយការណ៍ដើម ។ អ៊ីចឹងខ្ញុំយល់ថា វិធាន៣១នេះ គឺជាចំណុចមួយដែលជាជម្រើស ដែលអាចជំរុញឲ្យយើងធ្វើការដោះស្រាយបានដោយយុត្តិធម៌ទៅលើបញ្ហានៃរបាយការណ៍នេះ ដែលទៅតាមទស្សនៈរបស់ខ្ញុំ យើងត្រូវចាត់ទុកថា គឺជាវិធាន ហើយមិនមែនគ្រាន់តែជាអ្វីដែលយើងគ្រាន់តែមើលហើយចោលនោះទេ ។ ហើយក៏មិនមែនពីព្រោះ ដោយមិនមែនដោយសារគាត់ហ្នឹង គឺជាមេធាវីការពារក្ដីនោះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន តើខ្ញុំអាចឆ្លើយតបបានទេ?

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៥:៤០]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

មុននឹងយើងស្តាប់ លោក ហ្វ្រង់ស្វ័រ រូ មានបញ្ហាមួយដែលយើងគួរត្រូវលើកឡើង ខាងសហព្រះរាជអាជ្ញាបានបង្ហាញថា ពួកគេត្រូវទទួលបានការអនុញ្ញាតពីប្រធាន គឺសហព្រះរាជអាជ្ញា លោកស្រី ជា លាង និង លោក រ៉ូប៊ីត ពើទីត ។ អ៊ីចឹង ខ្ញុំយល់ថា បើសិនជាអាចគឺថាសុំឲ្យពួកគាត់ទាំងពីរអញ្ជើញមកនៅពេលនេះ ។ តើលោកអាចរៀបចំឲ្យពួកគាត់អញ្ជើញមកបានទេ? ដើម្បីយើងអាចសន្សំពេលវេលា នៅពេលដែលយើងកំពុងតែពិភាក្សាពីបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ។

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំមិនដឹងថាហេតុអ្វីបានជាដូចថាមានការលំបាកបែបនេះទេ សម្រាប់ខាងសហព្រះរាជអាជ្ញាខ្ញុំក៏បានយល់អំពីទឡ្ហីករណ៍ដែលបានលើកឡើងដោយលោកចៅក្រម ឡាវ៉ែន៍ និងលោក លោកស្រីចៅក្រមដទៃទៀត ។ អ៊ីចឹង យើងអាចមានជាសំណើមួយដើម្បីឲ្យយើងអាចដើរទៅមុខបាន ហើយប្រហែលជាខាងមេធាវីការពារក្តីអាចទទួលបាន ហើយវាស៊ីគ្នាទៅនឹងសេចក្តីសម្រេចរបស់លោកកាលពីម្សិលមិញ គឺខាងមេធាវីការពារក្តីមិនជំទាស់ទៅលើរបាយការណ៍ខែកក្កដា ឆ្នាំ២០០៧ ទេ ។ ហើយរបាយការណ៍នេះ គឺយោងទៅលើឯកសារចំនួន១៤៨ ហើយទៅតាមការយល់របស់ខ្ញុំ លោកចៅក្រម ឡាវ៉ែន៍ មានការមានការបារម្ភថា ឯកសារមួយចំនួនហ្នឹងឯង គឺមានជាច្រើនទំព័រ ហើយនេះអាចជាបញ្ហានៃការធ្វើសេចក្តីសង្ខេប ហើយមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើសេចក្តីសង្ខេបនោះ ។ អ៊ីចឹង មានន័យថា បើយើងធ្វើវិធីនេះ គឺថាមិនអាចធ្វើបានទេ ។ នៅក្នុងសវនាការពីមុនៗរបស់យើង នៅពេលដែលរបាយ-ការណ៍របស់អ្នកជំនាញត្រូវយកមកបង្ហាញ ឧបសម្ព័ន្ធផ្សេងៗទៀតនោះក៏ត្រូវយកមកបង្ហាញចំពោះមុខតុលាការដែរ ពីព្រោះនេះ គឺត្រូវបានចាត់ទុកជាឯកសារដែលជំនាញបានប្រើជាមូលដ្ឋាននៃការសរសេររបាយការណ៍របស់គាត់ ។ បើសិនជាយើងមើលទៅលើរបាយការណ៍របស់លោក គ្រេក អេតឆេសាន់ និយាយអំពីទស្សនាវដ្តីរបស់បក្សកុម្មុយនីស្តដែលមាន៣៤ទំព័រ ឧទាហរណ៍ ។ ហើយនៅទំព័រទី២២ គឺផ្តោតអារម្មណ៍តែទៅលើទំព័រ២២នៃរបាយការណ៍នេះតែប៉ុណ្ណោះ មានន័យថា នៅលើឯកសារអស់ទាំងហ្នឹង ដែលមានចំនួនច្រើន សម្រាប់ឯកសារនីមួយៗប្រហែលជាគាត់ប្រើកថាខណ្ឌតែមួយ ឬក៏តែមួយ

ទំព័រ ឬក៏តែពីរបីបន្ទាត់តែប៉ុណ្ណោះ ។ ដូច្នេះ សម្រាប់យើង យើងអាចចាត់យល់ថា យើងមានលទ្ធភាព នឹងអាចធ្វើបាន បើសិនជាអាចយើងធ្វើបានថា តើលោក ក្រេក អេតឆេសាន់ អាចពន្យល់អំពីទំព័រ ឬក៏កថាខណ្ឌនោះ ។

[១០:១៩:00]

ហើយនៅក្នុងសវនាការពីមុនៗមកដែលខ្ញុំចូលរួមនេះគឺជាការអនុវត្ត មានន័យថាគឺបង្ហាញតែទៅលើចំណុចពាក់ព័ន្ធ សម្រាប់ឯកសារនីមួយៗតែប៉ុណ្ណោះដើម្បីយកមកបង្ហាញនៅចំពោះមុខតុលាការ ។ ហើយមេធាវីការពារក្តី គាត់មិនជំទាស់ទៅលើរបាយការណ៍ឆ្នាំ២០០៧ នោះទេ ហើយរបាយការណ៍នេះត្រូវបានប្រើ ។ ដូច្នេះ យើងយល់ថា ឯកសារគាំទ្រហ្នឹង គឺជាដំណោះស្រាយគ្រប់គ្រាន់ត្រឹមត្រូវដើម្បីចៀសវាងក្នុងការបង្ហាញ ឬក៏ធ្វើសេចក្តីសង្ខេបឯកសារទាំងមូល ។ មានន័យថា លើកយកផ្នែកដែលពាក់ព័ន្ធតែប៉ុណ្ណោះ ទាក់ទងទៅនឹងរបាយការណ៍ ថាតើផ្នែកណាមួយនៃឯកសារនេះ ដែលគាត់បានយោងនោះ? ហើយប្រសិនជានៅពេលណាមួយខាងសហព្រះរាជអាជ្ញាចង់បង្ហាញអំពីឯកសារណាមួយដែលពួកគាត់ពឹងផ្អែកនោះ ពេលនោះ គឺថាគាត់ត្រូវធ្វើសេចក្តីសង្ខេប ឬក៏យកឯកសារអស់ទាំងហ្នឹងមកបង្ហាញឡើងវិញ ។

ខ្ញុំយល់ថា នេះគឺជាដំណោះស្រាយដ៏ប្រសើរបំផុត ។ មានន័យថា គឺរក្សាសិទ្ធិរបស់មេធាវីក្តីពីព្រោះគាត់អត់មានបញ្ហាជាមួយនឹងរបាយការណ៍ឆ្នាំ២០០៧ នោះទេ ហើយនិងឯកសារដែលត្រូវបានប្រើប្រាស់នោះយកមកបង្ហាញមុខ ចំពោះអង្គជំនុំជម្រះផងដែរ ។ ហើយខ្ញុំក៏បានដឹងច្បាស់ថា នេះគឺជាការបារម្ភរបស់អង្គសវនាការ ជាការចាំបាច់ណាស់សម្រាប់ឲ្យខ្ញុំលើកឡើងនិយាយអំពីបញ្ហានេះ ។

យើងនៅក្នុងស្ថានភាពមួយដែលរសើប ហើយក៏ជាចំណុចមួយដែលជាការបារម្ភផងដែរ គឺថាមានការបារម្ភដ៏ច្បាស់លាស់បំផុតអំពីអំឡុងពេលនៃសវនាការនេះ ។ ខ្ញុំចង់ចំណាយពេលវេលាមួយចំនួនដើម្បីនិយាយអំពីបញ្ហានេះ គឺថាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានស្លាប់ហើយកាលពីខែធ្នូ ។ អ៊ីចឹង គឺថាមានសេចក្តីបារម្ភផង ដែលថា សវនាការនេះគួរតែត្រូវបានដំណើរការទៅមុខ និងបញ្ចប់ឲ្យឆាប់រហ័សបំផុត ។ ហើយផ្នែកទីពីរនៃសំណើរបស់ខ្ញុំគឺថា មេធាវីទាំងអស់បាននៅម្ខាងនៃអង្គសវនាការនេះ គឺជាអ្នកដែលមិនបានទទួលប្រាក់ឧបត្ថម្ភពីតុលាការទេ ។ លោកចៅក្រម លោកមេធាវីការពារក្តី ខាងសហព្រះរាជអាជ្ញា អ្នកបកប្រែ មន្ត្រីតុលាការ គឺបានទទួលប្រាក់ខែពីតុលាការ ប៉ុន្តែក្រុមរបស់យើងខ្ញុំអត់បានទទួលប្រាក់ខែពីតុលាការទេ ។ នៅក្នុងក្រុមរបស់ខ្ញុំ គឺថា មានបុគ្គលិកប្រាំនាក់ធ្វើការនៅភ្នំពេញ

ហើយមិនបានទទួលប្រាក់ខែទេ គឺយើងបានទទួលយកភារកិច្ចនេះក្នុងគោលបំណងថា តុលាការសវនាការហ្នឹងឯង នឹងស៊ីពេល៣ ទៅ ៤ខែ ។ ហើយបើសិនជាសវនាការហ្នឹង វាលើសពីពេលនុ៎ង គឺថាយើងនឹងស្ថិតនៅក្នុងស្ថានភាពដ៏លំបាកបំផុត ។ ហើយសំណើនេះខ្ញុំយល់ថាគឺជាហេតុផលសមរម្យដើម្បីឲ្យពួកយើងអាចធ្វើដំណើរការធ្វើទៅមុខបាន ។ នេះគឺដើម្បីជាប្រយោជន៍ផងដែរ ដល់ខាងសហមេធាវី សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានមានចំណាប់អារម្មណ៍ដ៏ល្អនេះ ។

អញ្ជើញលោកស្រី ស្មូតហ្សីនស្តី ។

[១០:២២:២៨]

**លោកស្រី ស៊ីលឃីស្មូត ហ្សីនស្តី៖**

សូមអរគុណលោកប្រធាន ។ ជាបឋមខ្ញុំសូមលើកយោបល់បន្ថែមមួយ ហើយជាដំបូងនោះខ្ញុំសូមធ្វើការគាំទ្រចំពោះការដោះស្រាយ ដ៏សមហេតុផលទៅលើបញ្ហាឯកសារជាច្រើន ដែលបានយោងនៅក្នុងរបាយការណ៍របស់លោកបណ្ឌិត អេតឆេសាន់ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំយល់ឃើញថា ឯកសារទាំងនេះគឺវាពាក់ព័ន្ធ ហើយវាជាផ្នែកដែលបានយោងនៅក្នុងរបាយការណ៍ ។ ខ្ញុំមិនមានគំនិតរួមដូចខាងមេធាវីការពារក្តីដែលចង់ធ្វើការកម្រិតបទចោទចំពោះតែ ស-២១ ហើយមិនចូលទៅអង្គហេតុដទៃទៀត ។ ហេតុអ្វីបានជាដូច្នោះ? ដោយសារតែវាមិនមែនជាអង្គហេតុតែមួយតែប៉ុណ្ណោះ ដែលប្រព្រឹត្តឡើងទេ គឺវាអាចជាប់ពាក់ព័ន្ធគ្នា ។ ហើយនេះភារកិច្ចរបស់អង្គសវនាការក្នុងការពិនិត្យទៅលើប្រព័ន្ធ ការវាយប្រហារជាលក្ខណៈប្រព័ន្ធទៅលើប្រជាជន ។ ការវាយប្រហារនោះ គឺវារួមមានការវាយខុសៗ ដូចជា ពលកម្មដោយបង្ខំ និងអំពើដទៃៗទៀត ។

ដូច្នេះ យើងខ្ញុំ ដូចដែលអង្គសវនាការបានរំឭកហើយ គឺយើងបានបំបែកបញ្ហាទាំងមូលនេះជាផ្នែកនៃអង្គហេតុតូចៗ នៅពេលនេះយើងនិយាយអំពីមាគ៌ាបក្សរបស់កុម្មុយនីស្តកម្ពុជា និងការអនុវត្តមាគ៌ាបក្ស ។ ហើយនៅពេលនេះ គឺយើងមានអ្នកជំនាញនៅទីនេះ ដែលគាត់មកផ្តល់សក្ខីកម្មពាក់ព័ន្ធបញ្ហានេះ ។ ដូច្នេះ ខ្ញុំគិតថា វាជាបញ្ហាមួយសមហេតុផលក្នុងការពិភាក្សាដេញដោល ចំពោះមុខអង្គសវនាការទៅលើកភស្តុតាងទាំងអស់នេះ ។

ហើយវាធ្វើឡើងដោយស្របទៅតាមសេចក្តីសម្រេចរបស់អង្គសវនាការកាលពីម្សិលមិញដែល

ថា ភស្តុតាងឯកសារត្រូវតែធ្វើការសង្ខេប ។ ហើយប្រសិនបើអាចធ្វើទៅបាននោះ ខ្ញុំសូមធ្វើការគាំទ្រការយល់ឃើញរបស់ វ៉ែនណឺ លោក អាឡាំង វ៉ែនណឺ ដែលយើងយោងទៅលើផ្នែកដែលពាក់ព័ន្ធតែប៉ុណ្ណោះ ចំពោះឯកសារនោះ ។ ហើយប្រហែលជាយោងទៅលើកថាខណ្ឌ ដែលពាក់ព័ន្ធតែប៉ុណ្ណោះ ហើយគឺ ខ្ញុំសូមលើកឡើងថា វាមិនមែនជាឯកសារ និងភស្តុតាងថ្មីដូចដែលខាងមេធាវីការពារក្តីលើកឡើងម្តងហើយម្តងទៀតនោះទេ ។

[១០:២៦:០១]

ដើម្បីនិយាយសាជាថ្មីនោះ គឺថាដើម្បីខ្ញុំលើកឡើងសាជាថ្មី ទទ្ធីករណ៍របស់ខាងមេធាវីការពារក្តីហាក់ដូចជាបង្ហាញឲ្យឃើញថា គឺវាជាការពារដោយខ្លួនឯង ដោយមិនមានការយល់ឃើញពីខាងភាគីដទៃដូច្នោះនោះទេ ។ ដូច្នេះ ហើយដើមបណ្តឹងរដ្ឋប្បវេណី គឺចង់ឲ្យមានដំណើរការឲ្យលឿន ហើយចង់ឲ្យមានការស្វែងរកការពិតទាំងស្រុង ថាតើមានអ្វីកើតឡើងនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ? ហើយនេះជាភារកិច្ចរបស់អង្គសវនាការក្នុងការបង្ហាញនូវរូបភាពទាំងស្រុង ហើយយើងមិនបង្ហាញរូបភាពមួយចំនួនដូចស-២១ តែប៉ុណ្ណោះនោះទេ ។ ហើយខាងមេធាវីការពារក្តី ដូចលោក រូ បានស្នើឡើងកាលពីម្សិលមិញថា ឲ្យធ្វើការដេញដោលឲ្យបានលឿនបំផុតចំពោះអង្គហេតុផ្សេងៗ ។ យើងចង់ធ្វើដូច្នោះ ប៉ុន្តែ វាហាក់ដូចជាមិនបានបង្ហាញឲ្យបានច្បាស់ ថាតើវិសាលភាពនៃអ្វីដែលកើតឡើងពេញលេញនោះវាយ៉ាងម៉េច? ដូច្នេះហើយ យ៉ាងហោចណាស់វាជាផលប្រយោជន៍សម្រាប់ខាងផ្នែកដើមបណ្តឹងរដ្ឋប្បវេណីក្នុងការពិនិត្យនិងដេញដោលទៅលើភស្តុតាងទាំងអស់នោះ មុនពេលដែលភស្តុតាងទាំងអស់នោះយកមកធ្វើការដេញដោលនៅទីនេះ ។ ហើយអង្គហេតុនិងភស្តុតាងទាំងអស់នោះ នឹងបង្ហាញទៅដល់ការពិតចំពោះការវាយប្រហារដោយលក្ខណៈប្រព័ន្ធនិងរីករាលដាល ហើយអង្គហេតុទាំងនេះគឺវាមានសារសំខាន់ណាស់ក្នុងការបង្ហាញអង្គហេតុ និងសេចក្តីការពិតនៅមុខអង្គសវនាការ ។

ដូច្នេះ គឺខ្ញុំស្នើសុំអង្គសវនាការឲ្យធ្វើការផ្តល់តុល្យភាពទៅលើបញ្ហានេះ ហើយធ្វើការចងចាំថានេះជាគឺជាផលប្រយោជន៍ដ៏ចាំបាច់ក្នុងការធ្វើពិនិត្យដេញដោល ហើយយើងមិនអាចធ្វើការកម្រិតទៅតាមអ្វីដែលខាងមេធាវីការពារក្តីបានលើកឡើង និងគូសបញ្ជាក់ និងចង់បាននោះទេ ។ ប៉ុន្តែ យើងយ៉ាងហោចណាស់ត្រូវការស្វែងរកតុល្យភាពមួយឲ្យសមស្របទៅលើករណីនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មេធាវី សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

[១០:២៩:១៧]

**លោក ហ្វេង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកចៅក្រម លោក លោកស្រីចៅក្រមជាគោរព! ខ្ញុំសូមផ្តល់ចម្លើយមួយចំនួនតូច ចំពោះយោបល់ដែលលើកឡើង ដោយខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ជាថ្មីម្តងទៀត ខ្ញុំសុំស្នើនូវគំនិតមួយដែលវាអាចល្អចំពោះចំណុចទាំងអស់នេះ ។ ចំពោះគុណសម្បត្តិនៃអ្នកជំនាញក្នុងការលើកឡើងនូវយោបល់របស់ វ៉ាបេសាន់ជ្រាតាណា ។ សូមអរគុណ ដែលលើកឡើងអំពីវិធាន៣១ គឺវិធានដែលយើងត្រូវអនុវត្ត ។ វិធានទី៣១ គឺយោងដោយផ្ទាល់ទៅដល់ខាងសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ ។ ហើយនៅក្នុងករណីណាក៏ដោយវិធាន៣១ គឺមិននិយាយអំពីអ្នកជំនាញដែលជាផ្នែកមួយខាងមេធាវីការពារក្តី ឬក៏ខាងសហព្រះរាជអាជ្ញានោះទេ ។ វិធាន៣១ គឺចែងអំពីអ្នកជំនាញដែលគាត់ឯករាជ្យពីខាងមេធាវីការពារក្តី ឬក៏ពីខាងសហព្រះរាជអាជ្ញា ហើយនិងសហចៅក្រមស៊ើបអង្កេតនោះជាចំណុចច្បាស់លាស់ ។ ហើយខាងសហចៅក្រមស៊ើបអង្កេតអាចផ្តល់នូវអ្នកជំនាញដ៏ឯករាជ្យចូលរួមក្នុងការស៊ើបអង្កេត ។ តែនៅទីនេះលោក គ្រេក អេតធេសាន់ គឺមិនមែនជាអ្នកជំនាញឯករាជ្យទេ ហើយគាត់បានចូលរួមនៅក្នុងដំណើរការស៊ើបអង្កេត ។ ហើយគាត់បានចូលរួមក្នុងនាមជាសមាជិកការងារខាងក្រុមសហព្រះរាជអាជ្ញា ។ សូមអរគុណ ចំពោះមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចំពោះវិធានមួយនេះដែលបានឆ្លុះបញ្ចាំងយ៉ាងច្បាស់លាស់ ។

ដូច្នេះហើយយើងត្រូវការធ្វើការបែងចែកអំពីអ្នកជំនាញ និងលោក គ្រេក អេតធេសាន់ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ខ្ញុំសូមវិលត្រឡប់ទៅលើសំណើរបស់ខ្ញុំដំបូងវិញ មកទល់ខែកក្កដា ឆ្នាំ២០០៧ លោក គ្រេក អេតធេសាន់ គឺស្ថិតនៅក្នុងក្រុមសហព្រះរាជអាជ្ញា ប៉ុន្តែនៅពេលនោះមិនមានការចោទប្រកាន់លើបុគ្គលណាមួយនោះទេ ។ ហើយនៅពេលនោះ គឺគាត់បានបង្កើត ឬរៀបចំនូវរបាយការណ៍មួយដ៏សំខាន់ទៅលើស្ថានភាពនៃកម្ពុជាប្រជាធិបតេយ្យ ដែលរបាយការណ៍នោះ វាមានសារសំខាន់នៅចំពោះដំណើរការនីតិវិធីរបស់យើង ខ្ញុំសូមទទួលស្គាល់ ។

ហើយនៅក្នុងរបាយការណ៍នេះ គាត់ពឹងផ្អែកទៅលើឯកសារមួយចំនួនជាក់លាក់ ដែលឯកសារទាំងអស់នោះក៏មានផលប្រយោជន៍ផងដែរចំពោះដំណើរការក្តីរបស់យើង ។ ដូច្នេះហើយ ខ្ញុំសូមត្រឡប់ទៅលើវិធានទី៨៧ ដោយសារខ្ញុំជឿថា វាមានភាពយល់ច្រឡំនៅពេលដែលយើងនិយាយអំពីឯកសារ ។

ថាតើបញ្ហាឯកសារអ្វីដែលវាមានបញ្ហានៅទីនេះ? គឺទាក់ទងរបាយការណ៍របស់លោក គ្រេក

អេតឆេសាន់ ។ ឯកសារដែលយើងនឹងបញ្ចូលៗនៅក្នុងសំណុំរឿង គឺរបាយការណ៍របស់លោក ក្រេក អេតឆេសាន់។ ខាងមេធាវីការពារក្ដីបាននិយាយថា យើងៗអត់មានបញ្ហាចោទចំពោះរបាយការណ៍របស់លោក ក្រេក អេតឆេសាន់ នោះទេ ។ វាមានន័យថា យើងមិនមានការជំទាស់ចំពោះឯកសារដែលជាឧបសម្ព័ន្ធចំពោះរបាយការណ៍នោះទេ យើងអត់មានការជំទាស់នឹងបញ្ហានោះទេ ។

[១០:៣៣:០៣]

ដូច្នេះហើយ យើងកំពុងតែច្រឡូកច្រឡំបញ្ហានៅទីនេះ ចំពោះប្រភេទឯកសារពីរខុសគ្នា ។ យើងនៅទីនេះ គឺមានរបាយការណ៍របស់អ្នកជំនាញ ដែលរបាយការណ៍នេះភ្ជាប់ជាមួយនឹងឧបសម្ព័ន្ធ ដូច្នេះ យើងស្នើថា របាយការណ៍របស់អ្នកជំនាញក្រោយពីការតាំងសំណួរទៅដល់អ្នកជំនាញ និងភាគីនោះ យើងស្នើសុំថា ឲ្យរបាយការណ៍របស់អ្នកជំនាញនេះ គួរតែបញ្ចូលក្នុងសំណុំរឿងជាមួយនឹងឧបសម្ព័ន្ធផ្សេងទៀត ។

ប៉ុន្តែយើងមានការសោកស្ដាយ យើងមិនទទួលបានឯកសារបកប្រែចំពោះរបាយការណ៍នេះ នេះគឺជាចំណុចមួយច្បាស់លាស់ ។ ប៉ុន្តែជាថ្មីម្ដងទៀត ធាតុផ្សំចម្បងនៅទីនេះ ដែលគួរតែបញ្ចូលនៅក្នុងសំណុំរឿងនោះ គឺរបាយការណ៍នេះ ហើយប្រសិនបើនៅពេលក្រោយនៅក្នុងដំណើរការក្ដីរបស់យើង យើងចង់ប្រើប្រាស់ឯកសារ ដែលបានបញ្ចូលនៅក្នុងរបាយការណ៍នោះ យើងៗនឹងប្រើប្រាស់ឯកសារនោះដោយយើងយោងទៅលើរបាយការណ៍ ។

ចំណុចនេះ គឺវាខុសគ្នាពីឯកសារដែលសហព្រះរាជអាជ្ញាចង់ធ្វើការបង្ហាញនៅក្នុងលក្ខណៈឯក-រាជ្យ ខ្ញុំគួរតែនិយាយដូច្នោះ ចំពោះបញ្ហាអង្គហេតុជម្លោះប្រដាប់អាវុធ ។ ជាការពិតនៅទីនេះ សហព្រះរាជអាជ្ញាលើកឡើងថា មានឯកសារពីរយ, បីរយ ហើយគាត់ចង់បញ្ចូលដោយមិនចាំបាច់មានការគាំទ្រពីអ្នកជំនាញ ដូច្នេះយើងជួបបញ្ហាមួយផ្សេងនៅទីនេះ ។ ហើយអត់ឃើញមានអ្នកជំនាញ គាត់បញ្ជាក់អំពីរបាយការណ៍របស់សហព្រះរាជអាជ្ញា ដូច្នេះឯកសារពីរ-បីរយនោះ គឺមិនបានបញ្ចូល ទៅក្នុងរបាយការណ៍របស់ ណាយ៉ាន់ ចាន់ដា នោះទេ ។ ឯកសារទាំងអស់នោះ គឺសហព្រះរាជអាជ្ញា ចង់ដកចេញពីសំណុំរឿង ហើយចង់បង្ហាញជូនអង្គសវនាការមួយម្ដងៗ នេះជាការពិត ដែលបើយើង ចង់សង្ខេបនូវឯកសារនោះ យើងចំណាយពេលសប្ដាហ៍ពីរ-បីសប្ដាហ៍នោះ ។

ដូច្នេះ នេះគឺជា វាទាក់ទងទៅនឹងផ្នែកនៃឯកសារ ដែលទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ ដូចដែលខ្ញុំបានលើកឡើង ។ យើងមិនស្នើសុំឲ្យអានឯកសារនោះទាំងអស់នោះទេ យើងស្នើសុំថា សហព្រះ

រាជអាជ្ញា គួរតែផ្តល់នូវឯកសារតែមួយទំព័រសង្ខេបរបស់យើងក្រោមសេចក្តីណែនាំរបស់សហព្រះរាជអាជ្ញាថា ឯកសារមួយទំព័រនេះ គឺជាឯកសារផ្សេងៗដែលគាត់បានយោង ។ នៅពេលដែលខ្ញុំធ្វើការស្រាវជ្រាវ គឺខ្ញុំឃើញឯកសារនេះដើម្បីឲ្យខ្ញុំអាចតវ៉ាបាន ។

[១០:៣៦:១៩]

ដូច្នេះហើយខ្ញុំចង់ឲ្យខាងសហព្រះរាជអាជ្ញាធ្វើការផ្តល់ជូនតែមួយទំព័រថា តើមានអង្គហេតុអ្វីខ្លះដែលមាននៅក្នុងឯកសារ ពីរ-បីរយនោះទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ? ខ្ញុំសូមបន្ថែមថា ពាក់ព័ន្ធទៅនឹងអង្គហេតុជម្លោះប្រដាប់អាវុធ ខាងមេធាវីការពារក្តីបាននិយាយមុនហ្នឹងបន្តិចថា យើងមិនអន្តរា-គមន៍ចំពោះបញ្ហាចោទនេះទេ ដោយសារតែបញ្ហាចោទនេះ គឺទាក់ទងទៅនឹងសំណុំរឿងលេខ២ ហើយខ្ញុំចង់ទាញចំណាប់អារម្មណ៍អង្គសវនាការ ចំពោះវិធីសាស្ត្រដែលសហព្រះរាជអាជ្ញាកំពុងតែព្យាយាមធ្វើ។

សហព្រះរាជអាជ្ញាព្យាយាមធ្វើការសុំសេចក្តីសម្រេចពីអង្គសវនាការ ដែលវាផ្ទុយទៅនឹងចំណុចទាំងឡាយដែលបានចែងនៅក្នុងវិធីសាស្ត្រជាលក្ខណៈការទូត ដែលសហគមន៍អន្តរជាតិបានជឿថាជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងវៀតណាម ចាប់ផ្តើមនៅក្នុងខែធ្នូ ឆ្នាំ១៩៧៧ ហើយសហព្រះរាជអាជ្ញាចង់ឲ្យអង្គសវនាការ ។ យើងមិននៅទីនេះធ្វើការលើកឡើង-- សហព្រះរាជអាជ្ញាបានលើកឡើងអំពីបញ្ហាជម្លោះប្រដាប់អាវុធដែលកើតឡើងមុនឆ្នាំ១៩៧៧ នោះទៀត ។ ដូច្នេះហើយវាជាចំណុចខុសដែល យើងត្រូវធ្វើការសេចក្តីសម្រេចទៅលើបញ្ហានេះ ហើយនៅពេលនេះ យើងអត់មានវត្តមានរបស់លោក ខៀវ សំផន , អៀង សារី ដែលជាអ្នកជនត្រូវចោទផងដែរនៅទីនេះ ។

ដូច្នេះ ដោយស្របទៅតាមសហគមន៍ សេចក្តីសម្រេចរបស់សហគមន៍អន្តរជាតិនោះ គឺជនជាប់ចោទ គឺទទួលស្គាល់ថា មានជម្លោះប្រដាប់អាវុធយ៉ាងហោចណាស់ក្នុងឆ្នាំ១៩៧៧ ហើយនៅក្នុងឆ្នាំ១៩៧៨ គឺមានសង្គ្រាមដែលបានប្រព្រឹត្តឡើងនៅក្នុង ឧក្រិដ្ឋកម្មសង្គ្រាមដែលបានប្រព្រឹត្តឡើងនៅក្នុងស-២១ ។ ដូច្នេះ យើងមិនចាំបាច់មើលអង្គហេតុផ្សេងក្រៅពីហ្នឹងនោះទេ គាត់បានទទួលស្គាល់ហើយជនជាប់ចោទនោះ។

ដូច្នេះហើយ យើងត្រូវការបែងចែកអំពីស្ថានភាពដែលយើងជួបបញ្ហានៅទីនេះ ។ ទីមួយ គឺទាក់ទងរបាយការណ៍របស់លោក ក្រេក អេតធេសាន់ ខ្ញុំសូមលើកឡើងសាជាថ្មី នៅក្នុងរបាយការណ៍ខែកក្កដា ឆ្នាំ២០០៧ មុនពេលដែលគាត់មិនទាន់បានចូលរួមនៅក្នុងដំណើរការស៊ើបអង្កេត ។ ដូច្នេះ មេធាវីការពារក្តីមិនទទួលស្គាល់ថា ឯកសារទាំងអស់នោះគួរតែអាននោះទេ ដូច្នេះយើងអាចមានចំណុចរិះគន់

ផ្សេងៗទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ ហើយយើងធ្វើយ៉ាងណាយល់ឲ្យបានត្រឹមត្រូវចំពោះឯកសារទាំងអស់ ហើយឧបសម្ព័ន្ធទៅនឹងរបាយការណ៍ ហើយរបាយការណ៍នៅទីនេះ គឺយើងគួរតែយោងមើលវិធាន៨៧ ។ ហើយវិធាន៨៧ មិនមានចែងថា យើងគួរតែបញ្ចូលឯកសារផ្សេងៗដែលភ្ជាប់ទៅនឹងរបាយការណ៍នោះទេ អត់មានចែងនៅក្នុងវិធាន៨៧ នោះទេ ។ ដូច្នេះ មេធាវីការពារក្តីសូមស្នើយោងទៅតាមវិធាន៨៧ ឲ្យទទួលស្គាល់របាយការណ៍លោក ក្រេក អេតធេសាន់ ចុះខែកក្កដា ឆ្នាំ២០០៧ ។ ហើយចំពោះឯកសារថ្មីៗ ផ្សេងៗដែលសហព្រះរាជអាជ្ញាចង់ធ្វើការដាក់នៅមុខអង្គសវនាការ ដើម្បីគាំទ្រចម្លើយសម្ភាសរបស់លោក ក្រេក អេតធេសាន់ ទាំងអស់នោះ ខ្ញុំមិននិយាយឡើង វិញទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធនោះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

[១០:៤០:៤០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់លាស់ តើខ្ញុំបានយល់អំពីជំហររបស់មេធាវីការពារក្តី? បើសិនជាខ្ញុំយល់អត់បានច្បាស់លាស់ លោកបានបញ្ជាក់ថា ឯកសារដែលជារបាយការណ៍នោះ ហើយនិងឯកសារដែលជាឧបសម្ព័ន្ធនោះ ដែលជាឯកសារគាំទ្រទៅលើរបាយការណ៍នោះ ។ អ៊ីចឹង យើងត្រូវចាត់ទុកថាត្រូវបានដាក់នៅចំពោះមុខអង្គសវនាការនេះ ហើយនៅក្នុងអំឡុងពេលយើងសម្ភាសអ្នកជំនាញនេះ មិនចាំបាច់ធ្វើការអានឲ្យបានច្បាស់លាស់នោះទេ ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

ពិតមែនហើយលោកប្រធាន លោកចៅក្រម ។ ហើយនៅក្នុងដំណើរការ ដែលពេលឯកសារនោះត្រូវបានប្រើនោះ គឺឯកសារនោះត្រូវបានប្រើនៅពេលដែលយោងទៅលើរបាយការណ៍នោះ ហើយមិនត្រូវប្រើតែឯងនោះទេ ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤៦:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន សហព្រះរាជអាជ្ញាដែលធ្វើការចោទប្រកាន់នៅក្នុងអង្គសវនាការនេះ បានបង្ហាញថា ជាការប្រសើរណាស់បើសិនជាយើងមានវត្តមានរបស់លោកស្រី ជា លាង និង លោក រ៉ូបឺត ពេទីត នៅក្នុងអំឡុងពេលនៃការប្រជុំទាក់ទងទៅនឹងការគ្រប់គ្រងសវនាការនេះ ។ យើងមានការបារម្ភទាក់ទងទៅនឹងការឯកភាពគ្នាសម្រុះសម្រួលគ្នា  រវាងការអានសេចក្តីសង្ខេបនៃឯកសារនីមួយៗ ដែលមាននៅក្នុងឧបសម្ព័ន្ធរបាយការណ៍របស់លោក ក្រេក អេតឆេសាន់ ហើយនិងរក្សាតុល្យភាពនៃសវនាការឲ្យបានឆាប់រហ័យ ហើយនិងដោយមានប្រសិទ្ធភាព ។

អង្គសវនាការបានពិភាក្សានៅក្នុងអង្គប្រជុំនៃការគ្រប់គ្រងសវនាការនេះ គឺដើម្បីពិភាក្សាទៅលើបញ្ហានេះ ។ ហើយខ្ញុំមិនចង់រំឭកឡើងវិញអំពីការពិភាក្សាជាច្រើនដែលយើងបានធ្វើនោះទេ ប៉ុន្តែយើងបានមកដល់ដំណាក់កាលមួយដែលលោក ហ្វ្រង់ស្វ័រ រូ ជាប្រយោជន៍ណាស់បានធ្វើការទទួលស្គាល់ជាចំហ ។ ហើយគ្រាន់តែប្រកាសចំណុចកំណត់ចំណុចគំនិតរបស់គាត់នេះជាសាធារណៈ នៅពេលយើងមានសវនាការជាសាឡើងវិញ គឺថាគាត់ទាំងពីរ និងលោក ការ សាវុត្ថ បានទទួលស្គាល់នូវជំនាញរបស់លោក ក្រេក អេតឆេសាន់ ។

លើសពីនេះទៅទៀតខាងមេធាវីការពារក្តីបានទទួលស្គាល់ថា របាយការណ៍ ហើយនិងឧបសម្ព័ន្ធរបស់របាយការណ៍នោះ គឺថាបានដាក់បង្ហាញនៅចំពោះមុខអង្គសវនាការរួចហើយ ។

អ៊ីចឹង សម្រាប់អង្គសវនាការយើងយល់ថា វាមិនមែនជាការចាំបាច់ដើម្បីអានកំណត់ហេតុជាសង្ខេបនៃរបាយការណ៍នីមួយ នៃឯកសារនីមួយៗនោះទេ ។ ក៏ប៉ុន្តែបើសិនជាយើង ឬក៏ភាគីណាមួយចង់យោងទៅលើផ្នែកណាមួយនៃរបាយការណ៍ ហើយពេលនោះគឺលោក អេតឆេសាន់ នឹងមានកាតព្វកិច្ចដើម្បីយោងទៅលើឧបសម្ព័ន្ធណាមួយនោះ គឺថាឧបសម្ព័ន្ធនោះឯងត្រូវតែយកមកធ្វើសេចក្តីសង្ខេបនៅចំពោះមុខអង្គសវនាការ ។

ខ្ញុំសង្ឃឹមថា ខ្ញុំបានលើកឡើងជាសង្ខេបអស់ហើយទៅលើចំណុចសំខាន់ៗ លោក ហ្វ្រង់ស្វ័រ រូ បាននិយាយ បានលើកឡើង ហើយជាការ ជាប្រយោជន៍ដល់អង្គសវនាការប្រសិនបើលោកស្រី ជា លាង និងលោក រ៉ូបឺត ពេទីត អាចបញ្ចេញមតិយោបល់ ឬក៏ទទួល ឬក៏នឹងអាចជួយយើងបានទៅលើបញ្ហាលំបាកនៃដំណើរការនីតិវិធីនេះ ។ ហើយយើង គឺថាមានគំនិតមួយ ដើម្បីធ្វើការ ធ្វើវិសោធនកម្មទៅលើវិធាន ប៉ុន្តែនៅក្នុងអំឡុងពេលបច្ចុប្បន្ននេះ គឺយើងពុំអាចធ្វើបានទេ ។

[១០:៤៩:២៩]

**លោកស្រី ជា លាង៖**

សូមគោរពអង្គជំនុំជម្រះទាំងមូល! ក៏សូមអរគុណលោកស្រីចៅក្រមដែលបានអញ្ជើញព្រះរាជអាជ្ញាទាំងពីររូបនៅពេលនេះ ក្នុងការពាក់ព័ន្ធទៅលើឯកសារនានា ក្នុងការជំទាស់របស់មេធាវីការពារជនជាប់ចោទនោះ ។ អ្វីដែលខ្ញុំបានស្តាប់បានអម្បាញ់មិញនេះ តាមដែលខ្ញុំយល់ គឺថាមានរបាយការណ៍មួយចំនួនដែលលោកស្រីចៅក្រមលើកឡើងថា មិនបាច់ទាមទារនូវការអានទាំងអស់នោះទេ ។ ដោយអាន ដោយសង្ខេបៗអ្វីនេះ ដែលខ្ញុំយល់ ។ តើអ៊ីចឹងមែនទេ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

មេធាវីការពារក្តីបានទទួលស្គាល់នូវរបាយការណ៍និងឧបសម្ព័ន្ធរបស់របាយការណ៍របស់លោកក្រេក អេតធេសាន់ មានន័យថារបាយការណ៍ និងឧបសម្ព័ន្ធហ្នឹងគឺត្រូវបានដាក់បង្ហាញជូនទៅចំពោះមុខអង្គសវនាការរួចហើយ ។ ហើយនៅពេលដំណាក់កាលណាមួយដែលមិនត្រូវការយោងទៅលើឯកសារណាមួយនៅក្នុងឧបសម្ព័ន្ធនោះ មានន័យថា ឯកសារនោះឯងត្រូវយកមកអានជាសង្ខេប ឬក៏ត្រូវយកមកប្រគល់ឲ្យអង្គសវនាការ ។

**លោកស្រី ជា លាង៖**

ខ្ញុំបានយល់ហើយបញ្ហានេះ ដោយមេធាវីក៏គាត់បានទទួលស្គាល់តែបញ្ហាត្រង់ថា អានឬក៏មិនអានទេ បើសិនគិតទៅនោះ ហើយខ្ញុំគិតថា ភស្តុតាងក៏ដូចជារបាយការណ៍នេះ គឺមាននៅក្នុងសំណុំរឿងស្រាប់ហើយ ប៉ុន្តែ យើងត្រូវគិតថាអ្វីដែលសំខាន់ចំពោះសវនាការជាសាធារណៈ ក៏ដូចជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែរ នៅពេលដែលចេញសាលក្រម ។ តើសំអាងទៅភស្តុតាងអ្វី?

ដូច្នេះខ្ញុំយល់ថា ប្រសិនបើគិតឃើញថាភស្តុតាង ឬក៏របាយការណ៍ដែលមាននៅក្នុងសំណុំរឿងដែលយល់ថាមានសារសំខាន់ដើម្បីស្វែងរកយុត្តិធម៌នោះ យើងត្រូវតែបង្ហាញឲ្យសាធារណជន ក៏ដូចជាពិភពលោកបានដឹងអំពីថាជនជាប់ចោទនោះ បានប្រព្រឹត្តអ្វីខ្លះ?

[១០:៥២:០៧]

ខ្ញុំលើកករណីមួយ ឧទាហរណ៍ថាជនជាប់ចោទ គាត់បានឯកភាពទៅលើអ្វីដែលព្រះរាជអាជ្ញាបានលើកឡើង ។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានបង្ហាញអ្វីឲ្យសាធារណជនបានឃើញ ។ យើងបានដឹងតែចំពោះយើងជាចៅក្រម ជាព្រះរាជអាជ្ញា ជាបុគ្គលិកនៅធ្វើការនៅទីនេះទេ ។ ដោយឡែកសាធារណៈ

ជនគាត់អត់បានដឹងថា ជនជាប់ចោទនោះបានប្រព្រឹត្តអីខ្លះ? ហើយដើម្បីសេចក្តីសម្រេចផងនោះ ហើយគិតថាវាដើម្បីជាប្រយោជន៍និងយុត្តិធម៌ ហើយឃើញនឹងសេចក្តីសម្រេចថាយុត្តិធម៌ផងនោះ យើងគួរតែបង្ហាញនូវអ្វីដែលគាត់បានប្រព្រឹត្ត ។

បង្ហាញមិនមានន័យថា ត្រូវតែបង្ហាញនូវភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿងនោះទេ។ នោះអាស្រ័យទៅលើអង្គជំនុំជម្រះពិចារណាថាតើភស្តុតាងនៅក្នុងសំណុំរឿងនោះ មួយណាដែលសំខាន់ នេះជាឆន្ទានុសិទ្ធិក្នុងការសម្រេចរបស់អង្គជំនុំជម្រះដើម្បីស្វែងរកយុត្តិធម៌ហើយ ។ ព្រោះដូចយើងបានដឹងហើយថា ឯកសារនៅក្នុងសំណុំរឿងនេះ សហព្រះរាជអាជ្ញាគាត់ទទួលស្គាល់ថាវាមានឯកសារច្រើន ។ ដូច្នេះ មិនមែនមានន័យថា ឲ្យអង្គជំនុំជម្រះយកទាំងអស់នោះមកបង្ហាញនោះទេ ។ អានេះជាគំនិតរបស់ខ្ញុំ ប៉ុន្តែក៏មិនត្រូវបំបាត់អ្វីដែលភស្តុតាងដែលបង្ហាញថា ជនជាប់ចោទនោះបានប្រព្រិត្តបទល្មើសនោះដែរ ។ បើយើងបំបាត់មួយផ្នែក ហើយយើងទៅយកតែចំណុចតវ៉ាមកតវ៉ា វាហាក់ដូចជាអត់មានឃើញអ្វីដែលបានដាក់បន្ទុកទៅលើជនជាប់ចោទនោះទេ ។ អានេះជាយោបល់របស់ខ្ញុំ ។ ហើយខ្ញុំទុកឲ្យខាងសហព្រះរាជអាជ្ញាអន្តរជាតិ ប្រសិនជាគាត់មានយោបល់បន្ថែមទៅលើចំណុចនេះ សូមឲ្យគាត់លើកនិយាយបន្ថែមលើចំណុចនេះចុះ ។

[១០:៥៤:១៣]

**លោក រ៉ូប៊ឺត ពើទីត៖**

លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំសូមអរគុណដែលខ្ញុំមានឱកាសនៅព្រឹកនេះ ដើម្បីជួយដល់អង្គសវនាការ ។ នៅក្នុងអាជីពរបស់ខ្ញុំ ខ្ញុំយល់ថារឿងធម្មតាណាស់ វាមានប្រយោជន៍បើសិនជាខ្ញុំមិននិយាយច្រើន ។ ប៉ុន្តែ បើខ្ញុំគិតថាជាការជាក់ស្តែងណាស់ មានការកែប្រែនូវគោលជំហររបស់មេធាវីការពារក្តី ហើយខ្ញុំចាត់ទុកថាការស្នើឡើងនោះ គឺជាដំណោះស្រាយដែលអាចទទួលយកបាន ហើយដូចជាការយល់ដឹងរបស់ខ្ញុំ ដូចដែលចៅក្រមបាននិយាយ របាយការណ៍ហ្នឹងគឺរួមបញ្ចូលទាំងឧបសម្ព័ន្ធ ។ ប្រសិបើអង្គជំនុំជម្រះពិចារណា គឺថាយើងជាចាត់ទុកថាឯកសារហ្នឹង ត្រូវបានដាក់បង្ហាញនៅចំពោះមុខអង្គសវនាការរួចហើយ ។ ដូច្នេះយើងអាចខាត់ទុកថា ឯកសារនុ៎ង ហើយនិងឧបសម្ព័ន្ធអាចត្រូវយកមកពិចារណាជាភស្តុតាងសម្រាប់ដីកាសម្រេចនៅដំណាក់កាលចុងក្រោយ ។ ហើយពេលហ្នឹងមេធាវីការពារក្តគាត់បានយល់ដឹងពីចំណុចនេះដែរ ។

[១០:៥៥:៣២]

ខ្ញុំជាថ្មីម្តងទៀត ខ្ញុំមិនអាចជួយអ្វីបានលើក្រៅពីអ្វីដែលខ្ញុំបាននិយាយទេ ពីព្រោះខ្ញុំយល់ថានេះជាដំណោះស្រាយមួយដែលមានហេតុផលសមរម្យ ។ ជាការពិតណាស់ នេះមិនមែនមានន័យថាសហព្រះរាជអាជ្ញាមិនមានសិទ្ធិនៅក្នុងដំណាក់ការនីតិវិធីណាមួយ ដើម្បីស្នើឲ្យអង្គសវនាការធ្វើការពិចារណាទៅលើឯកសារណាមួយសម្រាប់គោលបំណងណាមួយ ដែលសហព្រះរាជអាជ្ញាយល់ថាជាអត្ថប្រយោជន៍ដើម្បីធានាបាននូវយុត្តិធម៌នោះ ។ ប៉ុន្តែ ទាក់ទងនឹងសក្ខីកម្មរបស់លោក អេតឆេសាន់ ហើយទាក់ទងទៅនឹងភាពធ្វើឲ្យបានលឿន នៃដំណើរការសវនាការនោះ គឺថានេះជាដំណោះស្រាយដែលយើងអាចទទួលយកបាន ។

ហើយខ្ញុំមុនបញ្ចប់ ខ្ញុំសូមនិយាយថា ខ្ញុំបើមានការជំទាស់ដ៏មុឺងម៉ាត់ ចំពោះការលើកឡើងរបស់មេធាវីការពារក្តីព្រឹកមិញនេះ ដែលនិយាយថាសហព្រះរាជអាជ្ញាហ្នឹង ព្យាយាមកែ ឬក៏បង្វែរទិសដៅនៃសវនាការបន្ទាប់ ដោយឲ្យអង្គសវនាការអាននូវចំណុចផ្សេងនោះ ។ យើងបានយល់ដឹងច្បាស់ណាស់អំពីអ្វីដែលបានលើកឡើងទាក់ទងទៅនឹងការចោទប្រកាន់ដែលបានលើកឡើង ហើយដែលមានចែងនៅក្នុងដីកាដំណោះស្រាយ ។

យើងនឹងលើកឡើងពីបញ្ហាជម្លោះប្រដាប់អាវុធនៅដំណាក់កាលសមរម្យ ប៉ុន្តែជាថ្មីម្តងទៀត ខ្ញុំចង់ធ្វើឲ្យកំណត់ហេតុហ្នឹងបង្ហាញថា គឺខាងសហព្រះរាជអាជ្ញា មិនមានគោលបំណងណាមួយនៅដំណាក់កាលណាមួយ ឲ្យពិចារណាសម្រេចទៅលើចំណុចណាមួយនោះទេ ។

ខ្ញុំសូមជំទាស់ទៅលើចំណុច ដែលខាងមេធាវីការពារក្តីបានលើកឡើង ទាក់ទងចំណុចនេះ ។ ដូចខ្ញុំនិយាយអ៊ីចឹងបើខ្ញុំនឹងដោះស្រាយ ខ្ញុំនឹងបង្ហាញមតិទាក់ទងទៅនឹងចំណុចនេះនៅពេលណាមួយ ។ ហើយខ្ញុំយល់ថាអ្វីដែលខ្ញុំបានលើកឡើងនេះ គឺអាចជួយដល់លោក លោកស្រីចៅក្រមបាន បើសិនជាខ្ញុំត្រូវការ ខ្ញុំនឹងអាចជួយបន្ថែមទៀត ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំចង់ធ្វើការបង្ហាញនូវការអង្កេតរបស់ខ្ញុំមួយទៀត ។ លោកនិងលោកស្រី ជា លាង មានវត្តមាននៅទីនេះ អង្គជំនុំជម្រះបានដឹងអំពីតុល្យភាពនៃសិទ្ធិរបស់សាធារណជន ហើយទៅនឹងដំណើរការនីតិវិធីឲ្យបានលឿននោះ ។ អ៊ីចឹង យើងចាំធ្វើការស្នើទៅខាងសហព្រះរាជអាជ្ញា ថាតើឯកសារចំនួនពីរ ឬបីនៃឧបសម្ព័ន្ធរបស់របាយការណ៍នោះ ដែលពាក់ព័ន្ធជាក់លាក់បំផុតទៅលើប្រធានបទនៅក្នុងអង្គសវនាការនេះ? ហើយធ្វើសេចក្តីសង្ខេបទៅលើឯកសារទាំងនោះ ។ ប៉ុន្តែ គឺថាកុំឲ្យធ្វើសេចក្តីសង្ខេបលើសពី

ឯកសារពីរ-បី ។ ប្រហែលជាមិនមែនជាការចាំបាច់នោះទេ ដោយយោងទៅលើអ្វីដែលខាងមេធាវីការពារក្តីបានព្រមព្រៀងនោះ ។ មានន័យថាអ្វី គឺថាយើងព្យាយាមធ្វើការរួមគ្នា ហើយមិនមែនធ្វើការប្រឆាំងគ្នាទៅវិញទៅមកនោះទេ ។

[១០:៥៨:៤៥]

អ៊ីចឹងជាការប្រសើរណាស់ ប្រសិនបើសិនជាយើងពិចារណាទៅលើប្រធាន ដែលយើងកំពុងតែពិចារណានោះ ។ អ៊ីចឹងប្រហែលជាខាងសហព្រះរាជអាជ្ញាអាចធ្វើការពិចារណាទៅលើលទ្ធភាព ដែលពួកគេអាចអាន ។ អានតែពីរបីឯកសារបានហើយ ដែលពាក់ព័ន្ធដើម្បីឲ្យសាធារណជន គាត់បានយល់ដឹងអំពីឯកសារឧបសម្ព័ន្ធនេះ ។

តើខ្ញុំអាចនិយាយ សួរជាមួយខាងមេធាវីការពារក្តីបានទេ? ប្រហែលខ្ញុំយល់ថា លោកមិនចាំបាច់ធ្វើការឆ្លើយតបទៅនឹងអ្វីដែលលោក រ៉ូប៊ីត ពេទីត បានលើកឡើងនោះទេ ពីព្រោះអ្វីដែលលោកបានធ្វើគឺជាអត្ថប្រយោជន៍ណាស់ ។

**ប្រធានអង្គជំនុំ៖**

បង្អង់មួយពេលសិន ដើម្បីទុកអ្នកបច្ចេកទេស ដើម្បីរៀបចំប្តូរ *ឌីស* ព្រោះឥឡូវអស់ *ឌីស* ហើយ រង់ចាំបន្តិចសិន ពីព្រោះមានបញ្ហា *ឌីស* ដែលអស់ត្រូវដូរ *ឌីស* ថ្មី ដើម្បីថតសំឡេង ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ឥឡូវនុំងរៀបរយរួចហើយ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំមិនធ្វើការឆ្លើយតបទៅនឹងអ្វីដែលបានលើកឡើងនោះទេ ប៉ុន្តែវាទាក់ទងទៅនឹងបញ្ហាចោទដែលខ្ញុំបានស្នើឡើងពីមុន ។ ខ្ញុំចង់លើកឡើងថា មុនពេលដែលយើង-- បន្ទាប់ពីយើងបានធ្វើការពិភាក្សាដេញដោលជាសាធារណៈចំពោះរបាយការណ៍ និងឧបសម្ព័ន្ធរបស់លោក ក្រេក អេតធេសាន់ ខ្ញុំចង់ឲ្យធ្វើការបោះពុម្ពរបាយការណ៍នេះ នៅក្នុងគេហទំព័រ ។ ខ្ញុំយល់ស្របជាមួយនឹងលោកស្រី ជា លាង ដែលថា សាធារណជនត្រូវតែទទួលបានព័ត៌មានឲ្យបានហ្មត់ចត់នូវអ្វីដែលកើតឡើងនៅទីនេះ ។

ហើយខ្ញុំយល់ឃើញថា ឯកសារដែលវាសម្ងាត់ ហើយបន្ទាប់មកខ្ញុំនឹងដេញដោលជាសាធារណៈនឹងក្លាយទៅជាឯកសារសាធារណៈ ហើយសាធារណជន គាត់គួរតែអាចធ្វើការទទួលបានតាមលក្ខណៈ

សារព័ត៌ ឬក៏តាមប្រភពផ្សេងៗ ។ ហើយខ្ញុំគិតថា របាយការណ៍របស់ ក្រេក អេតឆេសាន់ និង ឧបសម្ព័ន្ធ គួរតែបញ្ចូលក្នុងគេហទំព័រ ។ ហើយខ្ញុំចង់បញ្ជាក់ឡើងវិញ ដោយមានវត្តមានលោកស្រី និង លោក រ៉ូបឺត ពើទីត នៅទីនេះ ។ ដើម្បីជៀសវាងភាពលំបាកលំបិនផ្សេងៗនោះ ខ្ញុំចង់ឲ្យលោក ក្រេក អេតឆេសាន់ ធ្វើការផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ ដោយកម្រិតទៅលើរបាយការណ៍ដែលគាត់បង្កើតឡើងក្នុងឆ្នាំ២០០៧ ខែកក្កដា ហើយនិងឧបសម្ព័ន្ធដែលចុះខែកក្កដា ឆ្នាំ២០០៧ តែប៉ុណ្ណោះ ។ ខ្ញុំមិនចង់ឲ្យ លោក ក្រេក អេតឆេសាន់ ក្រោយរយៈពេលនោះ ក្នុងដំណាក់កាលស៊ើបអង្កេតនោះទេ ។ ហើយប្រសិនបើ ក្រេក អេតឆេសាន់ ចូលរួមក្នុងដំណើរការស៊ើបអង្កេតហើយនោះ គាត់គួរតែចូលរួម ឬក៏មិនគួរលើកឡើងទៅលើបញ្ហានេះ ។

ដូច្នេះ យើងគួរតែធ្វើការបោះជំហាននៅក្នុងទិសដៅមួយសមស្រប ហើយយើងគួរតែកម្រិតយើងទាំងអស់គ្នានៅរបាយការណ៍ខែកក្កដា ឆ្នាំ២០០៧ ដោយមិនហួសព្រំដែនហ្នឹង ។ ហើយខ្ញុំចង់បន្ថែមថា អ្វីដែលខ្ញុំលើកឡើងវាមិនពាក់ព័ន្ធទៅនឹង*ដ្យាក្រាម* ដែលលោក អេតឆេសាន់ បានលើកឡើងដែលថាវាមានប្រយោជន៍ដំណើរការក្តីនោះទេ ហើយវាជាឯកសារថ្មី ខ្ញុំមានការសោកស្តាយ ។ មេធាវីការពារក្តីទទួលបានឯកសារទទួលបានឯកសារនេះនៅពេលដែលឯកសារនេះបានបញ្ជាតែប៉ុណ្ណោះ ហើយវាមានការវិភាគផ្សេងៗនៅលើ*ដ្យាក្រាម* នោះ ហើយ *ដ្យាក្រាម* នោះ គឺមិនគួរយកមកពិភាក្សានៅក្នុងដេញដោលរបស់យើងនោះទេ ។

[១១:០៥:៥៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា ពើទីត ។

**លោក រ៉ូបឺត ពើទីត៖**

អរគុណលោកប្រធាន ។ ខ្ញុំនឹងលើកឡើងដោយខ្លីបំផុត ។ ខ្ញុំនឹងអនុញ្ញាតឲ្យសហសេវិករបស់ខ្ញុំលើកឡើងបញ្ហាទាក់ទងទៅនឹងការបោះពុម្ពផ្សាយទៅលើរបាយការណ៍នេះ ។ ហើយខ្ញុំសូមអនុញ្ញាតឲ្យសហសេវិកខ្ញុំនៅពេលបន្តិចទៀតលើកឡើងអំពីបញ្ហានៃការបោះពុម្ពនោះ ។ ហើយខ្ញុំចង់ឲ្យលោក អាឡិចសាន់ឌឺប៊ើត ព្យាយាមធ្វើការពិភាក្សាដេញដោល ហើយគាត់បានលើឡើងអំពីវិសាលភាពនៃរបាយការណ៍របស់លោក អេតឆេសាន់ ហើយ ។ ដូច្នេះហើយវាមិនជាការជួយពីខ្ញុំទេ នៅក្នុងការលើកឡើងទៅលើបញ្ហានុ៎ង ។

ដូច្នេះ ខ្ញុំស្នើសុំអង្គសវនាការ នៅពេលដែលអង្គសវនាការយល់ឃើញថា សមស្របហើយនោះ មុនពេលដែលយើងបើកជាសាធារណៈនោះ គឺខ្ញុំសម្រេចទៅតាមអង្គសវនាការ ហើយខ្ញុំចង់ឲ្យសហសេវិករបស់ខ្ញុំធ្វើការលើកឡើងអំពីបញ្ហានៃរបាយការណ៍នោះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី ជា លាង ។

**លោកស្រី ជា លាង៖**

សូមអរគុណ ហើយសុំបន្ថែមបន្តិចអ្វី ខ្ញុំមានពីរចំណុច ។ ទី១ ទាក់ទងទៅនឹងអ្វី ដែលលោកស្រីខាតវ៉ាយថ៍ លើកឡើងអំពីការថាអានឯកសារនោះ ។ ត្រង់ថាចំនួន គឺយើងមិនមានការកំណត់ត្រង់ថាពីរបីឯកសារនោះទេ ប៉ុន្តែយើងជាព្រះរាជអាជ្ញាគិតថា គួរតែយកភស្តុតាងណាដែលហួសពីវិមតិសង្ស័យទើបមកដាក់បន្ទុកជនជាប់ចោទ ។

ដូច្នេះ សូមឲ្យយល់ទៅលើពាក្យនេះ លើសពីវិមតិសង្ស័យ មានន័យដូចម្តេច ហើយនិងការអាននូវភស្តុតាងដាក់បន្ទុក ដើម្បីចោទប្រកាន់ជនជាប់ចោទនោះដូចម្តេច? នេះជាចំណុចទីមួយ ។

ដោយឡែកចំណុចទីពីរ ដែលលើកឡើងអំពីរបាយការណ៍ដែលដាក់ផ្សាយជាសាធារណៈនោះ ។ យើងជាសហព្រះរាជអាជ្ញាក៏មានឆន្ទៈដូចគ្នាថានឹងឲ្យនីតិវិធីដំណើរការហ្នឹង វាបានលឿនដូចគ្នា ហើយក៏ចង់ឲ្យបានសាធារណជនបានដឹងអំពីហេតុការណ៍នានានៅក្នុងសម័យនោះដែរ ។ តែយើងសួរថា បាយការណ៍ទាំងនោះ តើវាប៉ះពាល់ទៅនឹងគោលការណ៍សម្ងាត់ដែលទាក់ទងនឹងសំណុំរឿង០០២ ដែរឬទេ? យើងមិនជំទាស់ទៅអ្វីដែលពេលយើងធ្វើសវនាការជាសាធារណៈ ហើយរបាយការណ៍នោះក់ទងងសំណុំរឿង០០១នោះទេ ។ ដោយឡែកសំណុំរឿង០០២ ប្រសិនបើមានការប៉ះពាល់នូវអ្វីដែលរបាយ-រណ៍ខាងអ្នកជំនាញលើកឡើងនោះ គឺខាងព្រះរាជអាជ្ញាសូមឲ្យរក្សាការសម្ងាត់រហូតដល់មានសវនាការសាធារណៈទៅលើជនសង្ស័យទាំងបួនលើកក្រោយ ។ នេះជាសំណូមពររបស់ខ្ញុំមានពីរចំណុចហ្នឹង។ សូមអរគុណ មានប៉ុណ្ណឹង ។

[១១:០៩:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ។

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ហើយសូមគោរពអង្គជំនុំជម្រះ ។ ខ្ញុំមានការកត់សម្គាល់ឃើញពីរចំណុចដែលត្រូវលើកឡើង ។ ចំណុចទី១ ដូចលោកស្រី ជា លាង គាត់បានលើកឡើងហើយ ទាក់ទងទៅនឹងគោលការណ៍បញ្ហាភស្តុតាង ។ គឺថាគោលការណ៍នៃការបង្ហាញភស្តុតាង ក៏មានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញយើងដែរ គឺថាត្រូវតែបង្ហាញឲ្យលើសពីវិមតិសង្ស័យ ដើម្បីឲ្យចៅក្រមពិចារណា ។

ដូច្នេះ ក៏មិនមានបញ្ញត្តិណាមួយ ហើយក៏មិនមានភាគីណាមួយអាចកំណត់ ឬក៏តម្រូវថា ត្រូវតែបង្ហាញឯកសារចំនួនប៉ុណ្ណេះ ឬក៏ចំនួនប៉ុណ្ណោះ បានវាស្មើនឹង ឬក៏លើសពីវិមតិសង្ស័យនោះបានទេ ។ ហើយវាជាគោលការណ៍មួយដែលត្រូវតែព្រះរាជអាជ្ញាខិតខំប្រឹងប្រែងការងាររបស់ខ្លួន ដើម្បីបង្ហាញទៅឲ្យចៅក្រមពិចារណាឲ្យលើសពីវិមតិសង្ស័យ ។ នេះជាចំណុចសំខាន់ ។

ទាក់ទងទៅនឹងការបោះពុម្ពនៅក្នុង*វេបសាយ* ខ្ញុំក៏ឯកភាពជាមួយអ្នកស្រី ជា លាង ដែរ អាហ្នឹងមួយ ។ បញ្ហាមួយទៀត ការបោះពុម្ពនៅក្នុង*វេបសាយ* ឬក៏ផ្សាយជាសាធារណៈ មិនមែនជាការបង្ហាញភស្តុតាងជូនទៅចៅក្រម ដើម្បីពិចារណានោះទេ គឺបង្ហាញ គឺត្រូវតែបង្ហាញនៅក្នុងសវនាការនេះ មិនឲ្យចៀសផុតពីសវនាការនេះបានទេ ពីព្រោះថា ការបង្ហាញនៅក្នុងសវនាការនេះ ដើម្បីឲ្យចៅក្រមទាំងអស់ផ្តែកទៅលើអ្វី ដែលបានលើកឡើងនៅក្នុងសវនាការនេះ ។

ដូច្នេះ ភាគីនៃខាងមេធាវីការពារក្តី គាត់មានសិទ្ធិគ្រប់គ្រាន់នៅក្នុងការតវ៉ាជំទាស់នៅឯកសារនីមួយៗបាន ប៉ុន្តែមិនមានសិទ្ធិកំណត់ថា បង្ហាញឯកសារនេះ ឬតម្រូវថាចំនួនប៉ុណ្ណេះសន្លឹកបានហើយ មិនអាចអ៊ីចឹងបានទេ ។

[១១:១១:២៩]

ហើយជាទីបញ្ចប់ទៀត ខ្ញុំសំណូមពរថា សាក្សី (សូមទោស) អ្នកជំនាញដែលគាត់មកបង្ហាញនេះ មុននឹងគាត់មក គាត់បានស្បថរួចជាស្រេចហើយ ។ គាត់ស្បថថា អ្វីដែលគាត់និយាយ គឺនិយាយតែការពិត ដូចដែលមានចែងនៅក្នុងមាត្រា១៥៤នៃក្រមនីតិវិធីព្រហ្មទណ្ឌអ៊ីចឹង ដែលយើងមកប្រើ គឺយើងគាត់ស្បថរួចហើយ ដែលយក ដែលគាត់មកឡើងនិយាយនេះ ។ ដូច្នេះ អ៊ីចឹងយើងទទួលការពិតទៅតាមសម្បថនៃសាសនារបស់គាត់ ។ ហើយមាត្រា៣៣២នៃក្រមនីតិវិធីព្រហ្មទណ្ឌ គាត់ផ្តល់ឆន្ទានុសិទ្ធិឲ្យទៅអង្គជំនុំជម្រះសម្រេចស្តាប់ចម្លើយសាក្សីនីមួយៗនៅក្នុងសវនាការដែរ ។ សូមអរគុណ សូមអស់យោបល់ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមឲ្យធ្វើការបំភ្លឺ ត្រឹមតែដែរឬទេ? ដែលថានៅពេលនេះ យើងមានវិធីចំនួនបីក្នុងដាក់ភស្តុតាងចំពោះមុខអង្គសវនាការ គឺការអាននូវឯកសារ ធ្វើការសង្ខេបទៅលើឯកសារ ឬក៏តាមរយៈការយល់ស្របគ្នា ឬក៏ការប្រកាសចំពោះការយល់ព្រមព្រៀងគ្នាទៅលើវិធីសាស្ត្រនេះ ។ ហើយតាមរយៈការប្រកាសពីខាងមេធាវីការពារក្តីនេះ គឺយើងមិនគួរចាត់វិធានការផ្សេងណាទៀតក្នុងការពិចារណាទៅលើឧបសម្ព័ន្ធ ឬក៏របាយការណ៍ ។ ប៉ុន្តែ យើងត្រូវតែពិនិត្យមើល និងចាត់វិធានការទៅលើរបាយការណ៍ឧបសម្ព័ន្ធរបស់លោក ក្រេក អេតធេសាន់ដែលបានដាក់ជូនអង្គសវនាការដើម្បីយកមកធ្វើជាមូលដ្ឋាននៃសាលក្រមស្ថាពរ ។ ខ្ញុំសូមឲ្យធ្វើការបំភ្លឺទៅលើចំណុចនេះ ។ ថាតើខ្ញុំលើកឡើងត្រូវដែរឬទេ? គឺយើងមានបីរបៀបក្នុងការស្នើឡើងដូច្នេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលវ៉ា ខាតវ៉ាយថ៌៖**

ខ្ញុំប្រហែលជាមិនអាចពន្យល់បានច្បាស់លាស់ទាក់ទងទៅនឹងនីតិវិធីច្បាប់ស៊ីវិលនោះទេ ប៉ុន្តែឯកសារទាំងនេះ តាមការទទួលស្គាល់ពីខាងមេធាវីការពារក្តី គឺទាក់ទងទៅនឹងរបាយការណ៍ និងឧបសម្ព័ន្ធរបស់របាយការណ៍ដែលបានដាក់ជូននៅចំពោះមុខអង្គសវនាការ អនុលោមតាមវិធាន៨៧ ផ្នែកណាមួយនៃរបាយការណ៍ ឬក៏ឧបសម្ព័ន្ធ គឺអាចយោងនៅពេលណាមួយក៏បានដែរ ហើយយោងដោយជាក់លាក់ ដើម្បីឲ្យអង្គសវនាការធ្វើការសម្រេច ថាតើឯកសារទាំងអស់នោះទទួលយកបានដែរឬទេ? ហើយយើងបានសម្រេចដំណាក់កាលទីមួយហើយ ។ ដំណាក់កាលបន្ទាប់ គឺទាក់ទងទៅនឹងការទទួលយកបាន ភាពអាចទទួលយកបាន ។

យើងព្យាយាមការអាននូវឯកសារយ៉ាងច្រើននៃឯកសារសង្ខេបដោយសារតែពេលខ្លះទៅឯកសារទាំងអស់នោះ គឺមិនអាចពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអង្គហេតុ ឬក៏សម្រាប់ការពិចារណារបស់អង្គសវនាការ ។ ប្រសិនបើយើងតវ៉ា ឬក៏យើងចង់គូសបញ្ជាក់ទៅលើឧបសម្ព័ន្ធណាមួយនោះ គឺយើងគួរតែអានសង្ខេបទៅលើឧបសម្ព័ន្ធទាំងនោះដោយជាក់លាក់ ។

ដើម្បីឲ្យច្បាស់លាស់នោះ គឺកំពុងតែពិភាក្សានឹងដោះស្រាយលើរបាយការណ៍ និងឧបសម្ព័ន្ធរបស់របាយការណ៍ ។ វាមិនមែនជាសេចក្តីសម្រេចថ្មីចំពោះបញ្ហានេះទេ តើខ្ញុំបានបំភ្លឺទៅលើអ្វីដែល

លោកស្រីបានស្នើឡើងហើយឬនៅ?

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

បើសិនជាអនុញ្ញាតឲ្យខ្ញុំបន្ត គឺបានឆ្លើយតបមួយផ្នែកចំពោះសំណួររបស់ខ្ញុំ ។ ហើយដើម្បីបញ្ជាក់បន្ថែមទៅលើចំណុចនេះ ហើយថាតើឧបសម្ព័ន្ធ ឯកសារនៅក្នុងឧបសម្ព័ន្ធនោះគឺមិនមានការតវ៉ាពីភាគី ថាតើអង្គសវនាការអាចយកមកផ្អែកសម្រាប់សាលក្រមស្ពាពរ ដោយមិនចាំបាច់អានទាំងស្រុង ឬក៏អានសេចក្ដីសង្ខេបដែរឬទេ? នេះជាសំណួររបស់ខ្ញុំ ។ អ៊ីចឹងខ្ញុំដឹងហើយថា វាទាក់ទងទៅនឹងភាពទទួលយកបាន ប៉ុន្តែបើសិនជាឯកសារនោះអត់មានការតវ៉ា ថាតើយើងអាចយកមកផ្អែកជាសាលក្រមដែរឬទេ ដោយមិនចាំបាច់អានសង្ខេប ឬអានទាំងស្រុង? ឬក៏នេះជាការយល់ព្រមពីខាងមេធាវីការពារក្ដី ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីអនុញ្ញាតឲ្យអង្គសវនាការប្រើប្រាស់ភស្តុតាងណាមួយក្នុងការផ្អែកទៅលើសាលក្រមនោះជាបឋម ភស្តុតាងគួរតែដាក់ដេញដោលនៅចំពោះមុខអង្គសវនាការ នៅអង្គហេតុដែលមានបញ្ហាចោទ។ ហើយទាក់ទងសំណើផ្សេងៗ ទាក់ទងនឹងរបាយការណ៍របស់អ្នកជំនាញ និងឧបសម្ព័ន្ធដើម្បីអាចដេញដោលនៅមុខសវនាការ ឬក៏របាយការណ៍ដែលធ្វើឡើងតាមជំនាញរបស់អ្នកសាក្សីជំនាញនោះ ។

[១១:១៨:២៨]

នៅពេលដែលភស្តុតាងបានដាក់នៅចំពោះមុខអង្គសវនាការ គឺភាគីអាចស្នើសុំអំពីភាពទទួលយកបាននៃរបាយការណ៍ ឬក៏ឯកសារ ហើយអាចតវ៉ាអំពីវិសាលភាព និងភស្តុតាងដែលគេបានបង្ហាញនោះ ។ ប៉ុន្តែ ប្រសិនបើមិនមានការពិភាក្សាដេញដោលនៅលើឯកសារទាំងអស់នោះទេ កាលដែលត្រឹមតែដាក់នៅក្នុងសវនាការនោះ គឺហើយការដេញដោលនោះគឺថាវាច្បាស់លាស់ហើយ ថាៗយើងអាចយកមកផ្អែកជាមូលដ្ឋាននៃសាលក្រមបាន ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានលោក លោក លោកស្រីចៅក្រម ជាទីគោរព ។ វាហាក់ដូចជាបង្ហាញច្បាស់លាស់ចំពោះខ្ញុំហើយ ។ ខ្ញុំចង់ផ្ដល់យោបល់ចំពោះបញ្ហាចោទដែលលើកឡើងដោយលោកស្រី ជា លាង ស្ដីពី

ការបោះពុម្ពផ្សាយជាសាធារណៈចំពោះឯកសារ ។ លោកស្រី ជា លាង ថាតើលោកស្រីគិតដែរឬទេថារបាយការណ៍លោក អេតធេសាន់ ហើយនិងឧបសម្ព័ន្ធនៅក្នុងរបាយការណ៍នោះអាចប៉ះពាល់ទៅដល់សំណុំរឿងទីពីរ ឬក៏យ៉ាងម៉េច? ហើយប្រសិនបើវាអ៊ីចឹងមែនយើងអាចពិភាក្សាជាសាធារណៈ។ យ៉ាងហោចណាស់ខ្ញុំគិតថា វាមិនដូច្នោះទេ ។ ខ្ញុំមិនគិតថាវាប៉ះពាល់ទេ ខ្ញុំមិនគិតថារបាយការណ៍របស់លោក ក្រេក អេតធេសាន់ និងឧបសម្ព័ន្ធនោះ គឺវាប៉ះពាល់ទៅដល់សំណុំរឿងលេខពីរនោះទេ ហើយយើងគួរតែបញ្ជាក់បញ្ហានេះឲ្យបានច្បាស់ចំពោះយើងខ្ញុំ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមិនប្រាកដថាតើអង្គជំនុំជម្រះហ្នឹង ត្រូវធ្វើសេចក្តីសម្រេចនៅពេលនេះទៅតាមការយល់ដឹងរបស់ខ្ញុំ គឺត្រូវមានការពាក់ព័ន្ធដល់សហព្រះរាជអាជ្ញា ។ ប្រសិនបើពួកគាត់ត្រូវឡើងនិយាយទៅលើបញ្ហានេះនៅ ឬក៏ទៅលើបញ្ហាផ្សេងទៀត ។ ខ្ញុំគិតថា យើងបានពិនិត្យអស់ហើយទៅលើអ្វីដែលជាប្រធានបទ ដែលជាចំណុចនៅក្នុងការពិភាក្សាទៅលើការគ្រប់គ្រងតុលាការ ត្រូវគ្រប់គ្រងសវនាការនេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

[១១:២១:៤០]

**លោកស្រី អេលីហ្សាប៉ែត រ៉ាបេសាន់ជ្រាតាណា៖**

ខ្ញុំនឹងនិយាយខ្លីទេលោកប្រធាន ។ ខ្ញុំមិនចង់ឲ្យអ្វីខ្ញុំនិយាយហ្នឹង គេយកទៅបកស្រាយផ្សេងទេ ។ ខ្ញុំមិនត្រូវឲ្យគេយកខ្ញុំហ្នឹងប្រើជាឧបករណ៍សម្រាប់និយាយអំពីអ្វីដែលខាងមេធាវីការពារក្តីចង់និយាយនោះ ។ មេធាវីការពារក្តីបាននិយាយអំពីភាពស៊ីចង្វាក់គ្នា អំពីការពិតដែលលោក ក្រេក អេតធេសាន់ ជាអ្នកជំនាញហ្នឹង ដែលគាត់ធ្វើការនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ។ មេធាវីការពារក្តីបានចោទថា នេះគឺជាចំណុចមួយដែលមិនអាចស្រមើស្រមៃដល់ទេ ចំណែកខ្ញុំវិញ ខ្ញុំយល់ថា ជាការត្រឹមត្រូវ ។

ដើម្បីលើកឡើងសេចក្តីសន្និដ្ឋាន អាស្រ័យទៅលើវិធាន៣១ ពីព្រោះមិនមានភាពស៊ីចង្វាក់គ្នានៅទីនេះទេ ពីព្រោះមាត្រាទី៣១ និយាយអំពីអ្នកជំនាញដែលបានជ្រើសតាំងឡើងដោយសហចៅក្រមស៊ើបអង្កេត ។ ហើយបាននិយាយយ៉ាងច្បាស់ថា អ្នកជំនាញនេះគឺថាអាចចូលរួមនៅក្នុងដំណាក់ ឬក៏សកម្ម-

ភាពស៊ើបអង្កេត ។ គោលបំណងនៃសេចក្តីសន្និដ្ឋានរបស់ខ្ញុំ គឺដើម្បីធ្វើការធានាដល់អង្គសវនាការ និង បំភ្លឺដល់ចំណុចនានានៃសកម្មភាពរបស់អ្នកជំនាញ ហើយខ្ញុំនៅតែរក្សាថា នៅក្នុងទស្សនៈរបស់ខ្ញុំបន្ទាប់ ឆ្នាំ២០០៧ គឺថាគាត់អាចបន្តរៀបចំរបាយការណ៍របស់គាត់ ដោយអាស្រ័យទៅលើអង្គហេតុដែលគាត់ បានដឹងនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេត ។ នេះគឺជាសេចក្តីសង្ខេបនៃអ្វីនៃសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ដែលខ្ញុំចង់ធ្វើឡើងពីមុនមកនោះ ។ ហើយនេះគឺជាការពន្យល់ ដូច្នេះហើយខ្ញុំបានធ្វើការជំទាស់ទៅលើ ការបកស្រាយ ដែលថា មេធាវីការពារក្តីបានធ្វើទៅលើសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ហើយដែលដូចជាមិន មានគោលបំណងល្អនោះ ហើយមេធាវីការពារក្តីដូចជាចង់និយាយថា ខ្ញុំនឹងឯងខ្លួនឯងផ្ទាល់ធ្វើការ តវ៉ាទៅលើរបាយការណ៍ ឬក៏អ្វីដែលកើតមានក្រោយឆ្នាំ២០០៧នោះ ។ ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំនិយាយ នោះ វាច្បាស់លាស់ហើយ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗសហព្រះរាជអាជ្ញា ។

**លោកស្រី ជា លាង៖**

ទាក់ទងនឹងអ្វីដែលលោក ហ្វ្រង់ស្វ័រ រូ ដែលលើកឡើងអម្បាញ់មិញ ដែលសួរមកខាងការិយា-ល័យសហព្រះរាជអាជ្ញានេះ ដែលទាក់ទងនឹងការចុះផ្សាយនៅលើវេបសាយអំពីរបាយការណ៍របស់អ្នក ជំនាញ ។ ចំពោះខ្ញុំ ខ្ញុំគិតថាសំណួរនេះ ទីមួយគឺទាក់ទងទៅលើចៅក្រមស៊ើបអង្កេត ដោយខ្ញុំខ្លួនឯង ផ្ទាល់គិតថា មានចំណុចខ្លះទាក់ទងទៅនឹងសំណុំរឿង០០២ ។

[១១:២៥:០៤]

ដូច្នេះ គួរតែសួរទៅចៅក្រមស៊ើបអង្កេត ក្នុងករណីដែលចុះទៅវេបសាយជាសាធារណៈនោះ វាប៉ះពាល់នឹងគោលការណ៍សម្ងាត់ ដែលសំណុំរឿង០០២ មិនទាន់បានបញ្ចប់នៅឡើយនោះ ។ តើវាប៉ះ ពាល់ឬទេ? អានេះ គួរបញ្ជាក់ទៅចៅក្រមស៊ើបអង្កេត ។ នៅក្នុងនេះដែរ ក៏មាននៅក្នុងសំណុំរឿង ស្រាប់ហើយ ហើយមេធាវីក៏បានឃើញដោយខ្លួនឯងនៅក្នុងសំណុំរឿងទាំងមូល ពីព្រោះយើងបានចុះ នៅក្នុងសំណុំរឿង ហើយយើងបានពិនិត្យមើលទាំងអស់គ្នា ។ ចំពោះខ្ញុំ ខ្ញុំគ្រាន់តែពិនិត្យជាទូទៅ វាមាន ប៉ះពាល់ឈ្មោះទៅលើបុគ្គលជនសង្ស័យទៅលើសំណុំរឿងក្រោយហើយ ។ អាហ្នឹង ដូច្នេះ ការសម្រេច ក្នុងការ គោលការណ៍សម្ងាត់នៃការស៊ើបអង្កេតនោះ គួរតែឲ្យចៅក្រមស៊ើបអង្កេតជាអ្នកពិចារណា និង សម្រេចថាប៉ះពាល់អត់? គាត់កំពុងតែស៊ើបអង្កេតនោះ ។

អានេះ ខ្ញុំគ្រាន់តែផ្តល់ជាយោបល់ប៉ុនន៎ុងទេ ហើយបើគាត់គិតថា មិនប៉ះពាល់ក្នុងការស៊ើបអង្កេតរបស់គាត់ក្នុងសំណុំរឿងក្រោយទេ ខ្ញុំមិនជំទាស់ទេ ប៉ុន្តែបើចៅក្រមស៊ើបអង្កេតគាត់ថា ទេគាត់ស៊ើបអង្កេតមិនទាន់បញ្ចប់ផង ។ អ៊ីចឹងប៉ះពាល់ទៅលើជនសង្ស័យបួននាក់ខាងក្រោយនោះ អាហ្នឹងជាសិទ្ធិរបស់ចៅក្រមស៊ើបអង្កេតហើយដែលគាត់យល់ឃើញ ។ សូមអរគុណប៉ុណ្ណឹង ។

[១១:២៧:២៤]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ យើងពិភាក្សាគ្នាគ្រោងថា ជជែកពិភាក្សានេះតែមួយម៉ោង យ៉ាងយូរមួយម៉ោងកន្លះទេ ឥឡូវគឺពេញមួយព្រឹកតែម្តង ហើយសូមអរគុណដែរ ដែលការចូលរួមបញ្ចាក់បន្ថែមពីសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ ។ ឥឡូវនេះ ក៏ពេលវេលានៃការពិភាក្សា ក៏ដូចជាល្មមសមនឹងអាចអង្គជំនុំជម្រះយកទៅពិចារណាបានហើយ។ ដូច្នេះ គឺជាកិច្ចបន្តសូមខាងមន្ត្រីតុលាការរៀបចំបើកវាំងននឡើងវិញ ហើយនិងខាងអ្នកបច្ចេកទេសភ្ជាប់សំឡេងនិងរូបភាពទៅខាងសាធារណជន ។

ហើយអង្គជម្រះប្រកាសសម្រាកដប់ប្រាំនាទី ដើម្បីទុកនូវការរៀបចំនេះ ហើយបន្ទាប់មកអង្គជម្រះនឹងប្រកាសអំពីលទ្ធផលនៃកិច្ចពិភាក្សានេះដល់សាធារណជន មុននឹងសម្រាកពិសាអាហារថ្ងៃត្រង់នោះ ៕

*[សវនាការសម្រាកពីម៉ោង ១១:២៨ នាទី ដល់ម៉ោង ១២:00 នាទី ]*